# ច្បាប់

# ស្តីពី

# នីតិវិធីព្រហ្មទណ្ឌ

# LAW

# ON

# CRIMINAL PROCEDURE

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ
លេខៈ ២១ ក្រ

ក្រឹត្យ
ក្រុមប្រឹក្សារដ្ឋ
នៃ
រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមត្រឹត្យលេខ 0៤ ក្រ ចុះថ្ងៃទី ១0 ខែ កុម្ភៈ ឆ្នាំ ១៩៨២

សំរេច

ប្រកាសអោយប្រើច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៣ នាសម័យប្រជុំលើកទី ២នីតិកាលទី១។

ធ្វើនៅភ្នំពេញ ថ្ងៃទី 0៨ ខែមីនា ឆ្នាំ ១៩៩៣
ជ. ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា និង ត្រា :ហេង សំរិន

<u>កន្លែងទទួលៈ</u>
-ខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា
-ខុទ្ទកាល័យរដ្ឋសភា
-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
-គ្រប់ទីស្តីការរដ្ឋមន្ត្រី និងស្ថាប័នថ្នាក់ប្រហាក់ប្រហែល
-គ្រប់គណៈកម្មាធិការប្រជាជនខេត្ត- ក្រុង
-រដ្ឋកិច្ច
-កាលប្បវត្តិ- ឯកសារ

ដើម្បីចម្លងចែក
អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ
ហត្ថលេខា និងត្រា
ចាន់ វ៉ែន

# ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងប្រាប់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្ត តាមដោយហ្មត់ចត់ ដើម្បីនឹងកំណត់អោយច្បាប់ នូវអត្ថិភាព នៃបទល្មើសព្រហ្មទណ្ឌណាមួយ ។

**មាត្រា ២.–**

បទល្មើសព្រហ្មទណ្ឌណាក៏ដោយ អាចបណ្តាលអោយមានបណ្តឹងពីរយ៉ាងផ្សេងពីគ្នា គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៣.–**

បណ្តឹងអាជ្ញាមានគោលបំណងផ្តន្ទាទោសរាល់អំពើ ដែលនាំអោយខូចសណ្តាប់ធ្នាប់ និងសន្តិសុខសា-ធារណៈក្នុងសង្គម ហើយទោសទាំងនោះមានចែងក្នុងច្បាប់ដែលចូលជាធរមានរួចហើយ ។

ដូច្នេះបណ្តឹងអាជ្ញាត្រូវខិតខំប្រឹងធ្វើយ៉ាងណា កុំអោយអំពើទាំងនោះមានកើតឡើងទៀត ដោយ បង្ខំអោយពិរុទ្ធជនទទួលទោសដែលមានចែងក្នុងច្បាប់ ។

**មាត្រា ៤.–**

មានតែមន្ត្រីដែលច្បាប់ប្រគល់សិទ្ធិអោយទេ ទើបធ្វើបណ្តឹងអាជ្ញាបាន ។

**មាត្រា ៥.–**

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើអោយបានការជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើ ល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះអោយអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តធន់ល្មមនឹង ព្យសនកម្មដែលខ្លួនបានទទួល ។

**មាត្រា ៦.–**

បណ្តឹងទាំងពីរ ពោលគឺ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី សូម្បីមានបច្ច័យទាក់ទងជាមួយគ្នា ជិត ស្និតយ៉ាងណាក៏ដោយ ក៏អាចត្រូវញែក ប្តឹងដោយឡែកពីគ្នាបានជាដរាប ។

**មាត្រា ៧.–**

បណ្តឹងអាជ្ញាមិនអាចសំរុះសំរួលបានដោយកិច្ចការណាមួយឡើយ ។

សាលាជំរះក្តី បង្រ្កាបបទល្មើសព្រហ្មទណ្ឌ ដែលនឹងមានចែងក្នុងមាត្រាខាងមុខកាលបើបានទទួលដឹងអំពី បទល្មើសព្រហ្មទណ្ឌណាមួយ ហើយត្រូវជំនុំជំរះបទល្មើសព្រហ្មទណ្ឌនោះ។ ការមិនគោរពតាមគោលការណ៏នេះត្រូវទុកជាបទល្មើសមិនព្រមជំនុំជំរះ ហើយបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់វិន័យរដ្ឋបាល ឬ ដាក់គុកពី ៦ថ្ងៃ ដល់ ១ ខែ។

**មាត្រា ៨.-**

ការធ្វើបណ្តឹងអាជ្ញា និងការជំរុញបណ្តឹងអាជ្ញានេះអោយមានដំណើរការជាមុខងាររបស់អយ្យការ ។

តាមគោលការណ៏នៅមហាអយ្យការ អគ្គរដ្ឋអាជ្ញារង និង រដ្ឋអាជ្ញធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់អគ្គរដ្ឋអាជ្ញាទោះជានៅក្នុងពេលដែលអគ្គរដ្ឋអាជ្ញាវត្តមាន ឬអវត្តមានក៏ដោយ ។

នៅអយ្យការខេត្ត-ក្រុងរដ្ឋអាជ្ញារងធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់រដ្ឋអាជ្ញាទោះជានៅក្នុងពេលដែលរដ្ឋអាជ្ញាវត្តមាន ឬអវត្តមានក៏ដោយ ។

**មាត្រា ៩.-**

បុគ្គលដែលយល់ឃើញថា ខ្លួនត្រូវបានរងគ្រោះដោយអំពើល្មើស អាចដាក់ពាក្យប្តឹងជាមួយការចោទប្រកាន់របស់រដ្ឋអាជ្ញាដើម្បីទាមទារសំណងជំងឺចិត្ត ។

**មាត្រា ១០.-**

ក្នុងករណីដែលពាក្យប្តឹងរបស់អ្នកក្តីណាមួយដែលយល់ថា ខ្លួនត្រូវរងគ្រោះដោយអំពើដែលខ្លួនយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌហើយតំណាងអយ្យការឥតបានឆ្លើយតបនឹងពាក្យរបស់ខ្លួន ឬ តំកល់ពាក្យរបស់ខ្លួនទុកមិនចាត់ការ អ្នកក្តីនោះអាចប្តឹងទៅសាលាឧទ្ធរណ៏បាន ។

**មាត្រ ១១.-**

បណ្តឹងអាជ្ញាធ្វើបានទៅលើជនទាំងអស់ក្នុងរដ្ឋកម្ពុជាដោយឥតប្រកាន់ពូជសាសន៏ សញ្ជាតិ សាសនា ភេទ ឋានៈក្នុងសង្គមឡើយ ។

**មាត្រា ១២.-**

បណ្តឹងរដ្ឋប្បវេណីអាចមានមូលដ្ឋានតែទៅលើបទឧក្រិដ្ឋ បទមជ្ឈឹម ឬ បទលហុណាមួយតែប៉ុណ្ណោះទេយ៉ាងណាមិញសាលក្រមទាំងឡាយដើម្បីប្រកាសបានថា បណ្តឹងរដ្ឋប្បវេណីអាចទទួលបាននោះត្រូវលើកឡើង និង ចង្អុលបង្ហាញដោយត្រឹមត្រូវតាមច្បាប់នូវហេតុការណ៏នៃបទល្មើសព្រហ្មទណ្ឌដែលបណ្តាលអោយមានការជួសជុលខាងរដ្ឋប្បវេណី ។

ម្យ៉ាងវិញទៀត ទាល់តែបទល្មើសព្រហ្មទណ្ឌនោះបណ្ដាលអោយមានការខូចខាតពិតប្រាកដទើបបាន ទោះជាការខូចខាតនោះមានតែខាងផ្លូវចិត្តក៏ដោយ ។

**មាត្រា ១៣.-**

មិនមែនគ្រាន់តែត្រូវអោយមានជាមួយគ្នានូវបទល្មើសព្រហ្មទណ្ឌ និង ការខូចខាតដែលបណ្ដាលមកពីបទល្មើសព្រហ្មទណ្ឌនោះតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវអោយមានថែមទៀតផងដែរវាងបទល្មើសទាំងពីរនេះ នូវទំនាក់ទំនងពីហេតុទៅផល ឬមានន័យម្យ៉ាងទៀតថា ត្រូវអោយការខូចខាតនោះជាលទ្ធផលផ្ទាល់នៃបទល្មើស ហើយវាកើតមានពិតប្រាកដ និងក្នុងបច្ចុប្បន្ន ។

**មាត្រា ១៤.-**

តាមគោលការណ៍ មានតែបុគ្គលដែលរងគ្រោះផ្ទាល់ដោយអំពើល្មើសណាមួយទេដែលអាចធ្វើបណ្ដឹងរដ្ឋប្បវេណីបាន ។ អាចធ្វើបណ្ដឹងរដ្ឋប្បវេណីក្នុងនាម និង ដើម្បីជាប្រយោជន៏បុគ្គលរងគ្រោះដោយអំពើល្មើសពីបទល្មើសបានដែរ គឺបុគ្គលដែលច្បាប់អោយជនរងគ្រោះនៅក្រោមអាណាព្យាបាលឬច្បាប់អោយអំណាចជាតំណាងបុគ្គលរងគ្រោះ ។

**មាត្រា ១៥.-**

បណ្ដឹងរដ្ឋប្បវេណីអាចធ្វើបានទៅលើជនទាំងអស់ដែលត្រូវជួសជុលការខូចខាតបណ្ដាលមកពីអំពើល្មើស គឺរួមមាន ចារី សហចារី និងអ្នកសមគំនិតព្រមទាំងបុគ្គលទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនៃអំពើល្មើសនោះ ។

បណ្ដឹងរដ្ឋប្បវេណី ធ្វើទៅលើបុគ្គលទទួលខុសត្រូវខាងរដ្ឋប្បវេណីនោះបានពីព្រោះជាបច្ច័យមួយនៃការទទួលខុសត្រូវលើបុគ្គលដែលខ្លួនទទួលដោយអនុវត្តបទបញ្ញត្តិនៃច្បាប់រដ្ឋប្បវេណី ។ ប៉ុន្តែអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី មិនត្រូវទទួលទោសដោយផ្ទាល់នឹងតែម្នាក់ឯងនោះទេ ។

**មាត្រា ១៦.-**

បណ្ដឹងរដ្ឋប្បវេណីអាចធ្វើបានក្នុងពេលជាមួយនឹងបណ្ដឹងអាជ្ញាដែរនៅចំពោះមុខចៅក្រមដដែលនោះ ។

បណ្ដឹងរដ្ឋវេណីអាចធ្វើដោយឡែកបាន ។ ក្នុងករណីក្រោយនេះ ការធ្វើបណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្អាកសិនកាលណាបណ្ដឹងអាជ្ញាមិនទាន់បានសំរេចជាស្ថាពរនៅឡើយ ។

**មាត្រា ១៧.-**

ជនរងគ្រោះដោយបទល្មើសព្រហ្មទណ្ឌណាមួយ ដែលបានដាក់ពាក្យប្ដឹងទៅចៅក្រមរដ្ឋប្បវេណី ដើម្បីទារសំណងជំងឺចិត្ត ហើយត្រូវបានទទួលសំណងជំងឺចិត្តហើយនោះមិនអាចមកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងចោទប្រកាន់ដោយអយ្យការទៅលើបទល្មើសដដែលនោះបានទេ ។

**មាត្រា ១៨.-**

គោលការណ៍នេះនឹងអាចអនុវត្តន៏បានតែកាលណាសាលាជំរះក្តីផ្នែករដ្ឋប្បវេណី និង សាលាជំរះក្តីផ្នែកព្រហ្មទណ្ឌបានទទួលពាក្យបណ្តឹងដូចគ្នា គឺដូចគ្នាទាំងកម្មវត្ថុ ទាំងហេតុ និង ទាំងគូភាគី ។

**មាត្រា ១៩.-**

សាលាជំរះក្តីខាងអាជ្ញា ដែលបានទទួលពាក្យបណ្តឹងរបស់ជនរងគ្រោះសុំទារសំណងជំងឺចិត្ត មិនត្រូវសំរេចតែអំពើបណ្តឹងអាជ្ញាហើយបង្អង់បណ្តឹងរដ្ឋប្បវេណីដើម្បីទុកសំរេចនៅពេលជំនុំជំរះផ្សេងទៀតទេ ។ បើសាលាជំរះក្តីនោះពុំទាន់បានទទួលការបំភ្លឺគ្រប់គ្រាន់ទេនោះ ត្រូវតែផ្អាកការជំនុំជំរះទាំងអស់ដើម្បីទុកសំរេចនៅពេលខាងមុខ ។

ប៉ុន្តែក្នុងករណីពិសេស ដែលសាលាជំរះក្តីមិនអាចវាយតំលៃចំនួនសំណងជំងឺចិត្តក្នុងពេលនេះបានទេ សាលាជំរះក្តីនេះត្រូវគ្រាន់តែទទួលថាពាក្យបណ្តឹងសុំទារសំណងជំងឺចិត្តនេះធ្វើឡើងត្រឹមត្រូវតាមច្បាប់ហើយ ហើយត្រូវផ្អាកការកំណត់អត្រានៃការខូចខាត ដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងជូនមកនៅពេលខាងមុខ ។

**មាត្រា ២០.-**

ពិតមែនតែតាមគោលការណ៍ចៅក្រមជំនុំជំរះរឿងណាមួយ ជាចៅក្រមជំនុំជំរះគ្រប់ករណីនៃរឿងនោះ មានន័យថា : ចៅក្រមទទួលជំនុំជំរះរឿងព្រហ្មទណ្ឌណាមួយ ចៅក្រមនោះមានសមត្ថកិច្ចសំរេចសេចក្តីលើគ្រប់បញ្ហាទាំងអស់ ដែលគូភាគីបានប្តឹងទៅខ្លួន ក៏ប៉ុន្តែនៅពេលជាមួយគ្នា និង ពេលកំពុងចាត់ការរឿងព្រហ្មទណ្ឌណាមួយនោះអាចមានបញ្ហាមួយកើតឡើង ហៅថា "បញ្ហាបន្ទាន់បង្ខំ " ដែលជាបញ្ហាមួយចាំបាច់ដើម្បីកំណត់បទល្មើស ហើយដែលសាលាជំរះក្តីផ្នែកព្រហ្មទណ្ឌពុំអាចដោះស្រាយបាន ។ ការណ៍នេះកើតមាន ពីព្រោះបញ្ហាដែលប្តឹងឡើងមកនោះជាបញ្ហានៃច្បាប់រដ្ឋប្បវេណីសុទ្ធសាធ ។

**មាត្រា ២១.-**

បញ្ហាបន្ទាន់បង្ខំមានពីរប្រភេទគឺ: បញ្ហាបន្ទាន់បង្ខំចំពោះបណ្តឹង និង បញ្ហាបន្ទាន់បង្ខំចំពោះសាលក្រម ។

មានបញ្ហាបន្ទាន់បង្ខំចំពោះបណ្តឹង កាលណាបណ្តឹងអាជ្ញាមិនអាចធ្វើបានទេ នៅពេលដែលបញ្ហាបន្ទាន់បង្ខំនេះពុំទាន់ដោះស្រាយជាស្ថាពរ ។

បញ្ហាបន្ទាន់បង្ខំចំពោះសាលក្រម គឺជាបញ្ហាដែលបណ្តាលអោយមានការផ្អាកដំណើរការនៃការចោទប្រកាន់សិន ។ មានន័យថាចៅក្រមផ្នែកបង្ក្រាបបទល្មើសបានទទួលលិខិតចោទប្រកាន់ត្រឹមត្រូវតាមច្បាប់ហើយ ប៉ុន្តែចៅក្រមនេះពុំអាចសំរេចដល់អង្គសេចក្តីបានឡើយ កាលណាពុំទាន់បានទទួលសេចក្តីសំរេចពីតុលាការរដ្ឋប្បវេណីជាមុនសិននោះទេ ។

**មាត្រា ២២.-**

បញ្ហាបន្ទាន់បង្ហំចំពោះបណ្ដឹង គឺជាបញ្ហាដែលអាចកើតមានបទឧក្រិដ្ឋ ឬមជ្ឈិមទាក់ទង នឹងអំពើនាំពង្រត់ ឬអំពើលាក់បំពួនទារក ។

ការចោទប្រកាន់ មិនអាចធ្វើសំរេចទេចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយដែលបំបាត់សភាពកំណើតបុគ្គលណាមួយ កាលបើពុំទាន់មានសាលក្រមណាមួយបានទទួលស្គាល់ជាមុនសិន នូវដំណក់ត្រកូលរបស់កុមារដែលសភាពបុគ្គលត្រូវបំបាត់ចោលនោះ ។

**មាត្រា ២៣.-**

បញ្ហាបន្ទាន់បង្ហំចំពោះសាលក្រម គឺជាករណីពិសេសទាក់ទិនទៅនឹងសិទ្ធិលើកម្មសិទ្ធិ ឬទាក់ទិនទៅនឹងរូបវត្ថុណាមួយ ហើយក៏ជាករណីពិសេសទាក់ទិននឹងអត្ថិភាពនៃអាពាហ៍ពិពាហ៍ក្នុងទ្វេពន្ធភាព ។

**មាត្រា ២៤.-**

នឹងចាត់ទុកថាមានបញ្ហាបន្ទាន់បង្ហំទាក់ទងទៅនឹងសិទ្ធិលើកម្មសិទ្ធិ ឬទាក់ទងទៅនឹងសិទ្ធិរូបវត្ថុណាមួយ "សិទ្ធិអាស្រ័យផល សិទ្ធិប្រើប្រាស់ ឬសិទ្ធិសេវភាព" នោះលុះត្រាតែសិទ្ធិលើរូបវត្ថុ ដែលលើកមកសំអាងក្នុងរឿងចោទប្រកាន់ព្រហ្មទណ្ឌជាសិទ្ធិលើអចលនវត្ថុ ។ប្រសិនបើវាគ្រាន់តែជាសិទ្ធិលើចលនវត្ថុប៉ុណ្ណោះទេ ចៅក្រមព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសំរេច ហើយវាមិនមែនជាបញ្ហាបន្ទាន់បង្ហំដែលត្រូវតែសំរេច ដោយសាលាជំរះផ្នែកក្ដីរដ្ឋប្បវេណីឡើយ ។

**មាត្រា ២៥.-**

សិទ្ធិកាន់កាប់ នឹងទៅជាបញ្ហាបន្ទាន់បង្ហំបាន ប្រសិនបើសិទ្ធិនោះត្រូវបានទទួលស្គាល់ដោយលិខិតស្នាមត្រឹមត្រូវតាមច្បាប់ ឬលិខិតស្នាមមានលក្ខណៈគ្រប់គ្រាន់គួរយកជាការបាន ។ ក្នុងករណីក្រៅពីនេះគឺថា ប្រសិនបើសិទ្ធិនោះគ្រាន់តែលើកឡើងដោយមានសាក្សីជាសំអាងតែប៉ុណ្ណោះទេនោះ វានៅតែស្ថិតក្នុងការវាយតំលៃនិងសំរេចរបស់សាលាជំរះក្ដីផ្នែកព្រហ្មទណ្ឌ ។

**មាត្រា ២៦.-**

សាលាជំរះក្ដី គ្មានសិទ្ធិលើកបញ្ហាបន្ទាន់បង្ហំដោយឯកឯងក្នុងរឿងសិទ្ធិលើកម្មសិទ្ធិលើរូបវត្ថុបានទេ បញ្ហានេះត្រូវលើកដោយជនជាប់ចោទទើបបាន ។

**មាត្រា ២៧.-**

បញ្ហាបន្ទាន់បង្ហំអាចលើកនៅពេលណាក៏បាន សូម្បីតែនៅពេលប្ដឹងឧទ្ធរណ៍ក៏លើកបានដែរ ។

**មាត្រា ២៨.-**

ក្នុងករណីចោទប្រកាន់អំពីទ្វេពន្ធភាព មោឃភាពនៃអាពាហ៍ពិពាហ៍ណាមួយក្នុងចំណោម អាពាហ៍-ពិពាហ៍ទាំងពីរអាចលើកឡើងបាន ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌដែលអង្គហេតុលើកឡើងមកនោះ វាធ្វើអោយមោឃភាពនោះមានពិតប្រាកដ ។

**មាត្រា ២៩.-**

កាលណាចៅក្រមព្រហ្មទណ្ឌទទួលស្គាល់ថា បញ្ហាបន្ទាន់បង្ខំដែលកើតឡើងនោះត្រឹមត្រូវតាមច្បាប់ ចៅក្រមនេះត្រូវផ្អាកការជំនុំជំរះសិនបើពុំនោះទេការជំនុំជំរះត្រូវទុកជាមោឃៈ ហើយចៅក្រមត្រូវកំណត់រយៈពេលវេលាអោយភាគីដែលលើកបញ្ហាបន្ទាន់បង្ខំប្តឹងទៅសាលាជំរះក្តីមានសមត្ថ-កិច្ច ។

**មាត្រា ៣០.-**

ក្នុងករណីណាក៏ដោយចៅក្រមមិនត្រូវអោយជនជាប់ចោទរួចខ្លួនដោយឥតបានជំនុំជំរះឡើយ ។

បើចៅក្រមយល់ឃើញថាករណីពិសេសដែលលើកឡើងនោះមិនអាចទទួលបានទេចៅក្រមត្រូវបដិសេធចោលតែម្តង ហើយត្រូវបន្តការជំនុំជំរះដោយបញ្ជាក់ដោយខានមិនបាននូវមូលហេតុនៃការសំរេចរបស់ខ្លួន ។ ប្រសិនបើសាលក្រមរបស់តុលាការពុំបានបញ្ជាក់ពីមូលហេតុដូចខាងលើនេះទេ សាលក្រមនេះមានមោឃភាពដាច់ខាត ។

**មាត្រា ៣១.-**

នៅពេលផុតកំណត់រយៈវេលាដែលមានចែងក្នុងមាត្រា ២៩ ហើយបើជនជាប់ចោទបញ្ជាក់ថា ខ្លួនបានប្តឹងទៅសាលាជំរះក្តីផ្នែករដ្ឋប្បវេណីមានសមត្ថកិច្ចពិនិត្យរឿងបន្ទាន់បង្ខំនោះរួចហើយ នោះរយៈវេលាថ្មីមួយអាច ត្រូវបានកំណត់ដើម្បីបានសាលក្រមស្តីពីបញ្ហានោះ ។ តំណាងអយ្យការត្រូវជំរាបដល់សាលាជំរះក្តីផ្នែករដ្ឋ-ប្បវេណីមានសមត្ថកិច្ចនោះនូវកាលបរិច្ឆេទនៃការផុតរយៈពេលនោះ ។

នៅពេលផុតកំណត់រយៈវេលានោះ ប្រសិនបើមានសេចក្តីសំរេចជាស្ថាពរណាមួយអំពីបញ្ហាបន្ទាន់បង្ខំនោះ នីតិវិធីត្រូវដំណើការឡើងវិញជាធម្មតា ។ បើគ្មានសេចក្តីសំរេចនេះទេ ហើយបើការយឺតយ៉ាវបណ្តាមកពីការធ្វេសប្រហែសរបស់ជនជាប់ចោទ នោះត្រូវចាត់ទុកថាជនជាប់ចោទបានបោះបង់ការលើកជាសំអាងនូវបញ្ហាបន្ទាន់បង្ខំនោះហើយ ។ សាលាជំរះក្តីផ្នែកព្រហ្មទណ្ឌត្រូវបន្តការជំនុំជំរះរបស់ខ្លួនតទៅទៀត ។

**មាត្រា ៣២.-**

បើជនជាប់ចោទជាដើមបណ្តឹងនៃករណីពិសេស ហើយបើជនជាប់ចោទនោះបានជូនមក នូវសាលក្រមសំរេចអោយខ្លួនឈ្នះក្នុងបញ្ហាបន្ទាន់បង្ខំ សាលាជំរះក្តីព្រហ្មទណ្ឌត្រូវទទួលស្គាល់សេចក្តីសំរេចនោះ ហើយត្រូវសំរេចអោយជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។

ប្រសិនបើជនជាប់ចោទចាញ់ក្តីក្នុងការជំនុំជំរះបញ្ចាបន្ទាន់បង្ខំ សាលាជំរះក្តីព្រហ្មទណ្ឌត្រូវសំរេចពីបណ្តឹងអាជ្ញា ដូចជាគ្មានការប្តឹងពីករណីពិសេសឡើយ ។

**មាត្រា ៣៣.-**

ការលះបង់បណ្តឹងរដ្ឋប្បវេណីមិនអាចបញ្ឈប់ ឬផ្អាកដំណើរការនៃបណ្តឹងអាជ្ញាបានឡើយ ។

**មាត្រា ៣៤.-**

បណ្តឹងអាជ្ញអាចរលត់ទៅបានក្នុងករណីខាងក្រោមៈ

-ជនល្មើសទទួលមរណៈភាព

-ការផុតអាជ្ញាយុកាលនៃបទល្មើស

-ការលើកលែងទោសជាទូទៅ

-ការដកបណ្តឹងរបស់អ្នកទទួលការខូចខាត ក្នុងរឿងព្រហ្មទណ្ឌមួយចំនួន ដូចជាការនាំពង្រត់អនីតិជន អាយុច្រើនជាង១៤ឆ្នាំ ដោយអនីតិជននោះស្ម័គ្រចិត្តការជេរប្រមាថដល់បុព្វញ្ញាតិ ។

## ជំពូកទី២

## អំពីនគរបាលយុត្តិធម៌

**មាត្រា ៣៥.-**

នគរបាលយុត្តិធមិស្វែងរកបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទាំងឡាយ ប្រមូលភស្តុតាង ហើយបញ្ជូនជនល្មើសទៅសាលាជំរះក្តីដែលមានភារកិច្ចផ្តន្ទាទោសជនទាំងនោះ ។ ប៉ុន្តែនឹងអាចត្រូវបានចាប់បញ្ជូនទៅសាលាជំរះក្តីដោយនគរបាលយុត្តិធមិ តែក្នុងករណីដែលជនល្មើសបានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ឬកាលណាមានដីកាបង្គាប់អោយនាំខ្លួន ឬដីកាចាប់ខ្លួនជនល្មើស ។

**មាត្រា ៣៦.-**

ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធមិ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធមិរួមមាន :

១-រដ្ឋអាជ្ញា និងចៅក្រមទទួលបន្ទុកស៊ើបអង្កេត"ក្នុងភារកិច្ចតែប៉ុណ្ណោះ"

២-ប្រធាន និង អនុប្រធានទាំងឡាយនៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ និងសេដ្ឋកិច្ច

៣-ប្រធាន និងអនុប្រធានទាំងឡាយនៃនាយកដ្ឋានប្រឆាំងភេរវកម្ម

៤-ស្នងការ និងស្នងការរងទាំងឡាយនៃនគរបាលខេត្ត-ក្រុង

៥-ប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌ និងសេដ្ឋកិច្ច

៦-ប្រធានការិយាល័យប្រឆាំងភេរវកម្ម

៧-ប្រធានការិយាល័យនគរបាលសន្តិសុខ

៨-អធិការ និងអធិការរងនគរបាលនយោបាយស្រុក-ទីរួមខេត្ត

៩-ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល "ចំពោះរឿងព្រហ្មទណ្ឌ"

១០-ប្រធានការិយាល័យនគរបាលចរាចរ និងប្រធានផ្នែកបទល្មើសចរាចរ "ចំពោះបទល្មើសចរាចរ"

១១-ប្រធាន និងមន្ត្រីទាំងឡាយនៃកងតម្រួតយោធា "ចំពោះបទល្មើសយោធា"

១២-មន្ត្រីនគរបាលព្រំដែន

១៣-អធិការគយ "ចំពោះបទល្មើសគយ"

១៤-មន្ត្រីរុក្ខាប្រមាញ់ និងនេសាទ

ប្រតិបត្តិការទាំងឡាយនៃនគរបាលយុត្តិធម៌ស្ថិតក្រោមការដឹកនាំផ្ទាល់របស់រដ្ឋអាជ្ញា និងក្រោមការត្រួតពិនិត្យរបស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ ។

**មាត្រា ៣៧.-**

មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចចាត់ចែងប្រតិបត្តិការគឺ :

-មន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងដែលបទល្មើសព្រហ្មទណ្ឌកើតមាន

-មន្ត្រីនគរបាលយុត្តិធម៌ ខាងលំនៅដ្ឋានរបស់ជនល្មើស

-ឬមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងដែលជនល្មើសត្រូវបានរកឃើញ

**មាត្រា ៣៨.-**

មន្ត្រីនគរបាលយុត្តិធម៌:

-ទទួលពាក្យបណ្តឹងទាមទារបណ្តឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ ទាក់ទងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុនានា ។

-ចាត់ចែងប្រមូលភស្តុតាងនានា ។

-អាចស្នើសុំជំនួយពីកំលាំងសារធារណៈ ។

-ធ្វើកំណត់ហេតុ ។

-អាចទទួលលិខិតបង្គាប់អោយសួរជំនួស ។

-អាចសំរេចឃាត់ខ្លួនបានក្នុងរយៈពេល៤៨ម៉ោងយ៉ាងយូរ ។

-ក្នុងករណីរឿងឧក្រិដ្ឋ និងមជ្ឈិមជាក់ស្តែង អាចសួរយកចំលើយសាក្សី ធ្វើការឆែកឆេរ និងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសំរេចឃាត់ខ្លួនជនល្មើស "៤៨ ម៉ោងយ៉ាងយូរ" ចាប់បុគ្គលណាមួយ ប្រសិនបើ

មានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់សមស្របធ្វើការចោទប្រកាន់បាន ។

**មាត្រា ៣៩.-**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវកត់ត្រាក្នុងលិខិតជាលាយលក្ខណ៍អក្សរដែលហៅថា "កំណត់ហេតុ" នូវការពិនិត្យឃើញរបស់ខ្លួន និងលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន ។

តាមគោលការណ៍ កំណត់ហេតុមិនមែនជាមូលដ្ឋានចាំបាច់នៃការចោទប្រកាន់ទេ ។ កំណត់ហេតុនោះគ្រាន់តែផ្តល់ធាតុផ្សំទាំងឡាយនៃបទល្មើសសំរាប់ជាមូលវិចារណ៍របស់អយ្យការ និងចៅក្រមតែប៉ុណ្ណោះ ។

**មាត្រា ៤០.-**

កំណត់ហេតុត្រូវកត់គោត្តនាម នាម និងមុខងាររបស់អ្នកធ្វើកំណត់ហេតុ ។ អ្នកធ្វើកំណត់ហេតុត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទក្នុកកំណត់ហេតុ ហើយត្រូវធ្វើកំណត់ហេតុនោះជាបន្ទាន់កុំអោយមានការយឺតយ៉ាវឡើយ ។ ការឆូត លុបឬការបន្ថែមសេចក្តីទាំងឡាយត្រូវមានសេចក្តីបញ្ជាក់ ។

**មាត្រា ៤១.-**

តាមគោលការណ៍ កំណត់ហេតុមានតំលៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ អាចនិយាយបានម្យ៉ាងទៀតថា កំណត់ហេតុមានតំលៃជាសេចក្តីរាយការណ៍ ហើយមិនបង្ខំសាលាជំរះក្តី ឬចៅក្រមត្រូវតែជឿនោះទេ ។

**មាត្រា ៤២.-**

ប៉ុន្តែកំណត់ហេតុរបស់នគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់"ឯកសារដើម" បានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ កាលបើកំណត់ហេតុទាំងនោះធ្វើឡើងដោយមន្ត្រីយុត្តិធម៌ខ្លួនឯង ។ ក្នុងករណីនេះ ចៅក្រមត្រូវទុកខ្លឹមសាររបស់កំណត់ហេតុថាជាសេចក្តីពិត និងត្រឹមត្រូវដរាបណាដែលគ្មានភស្តុតាងអ្វីផ្ទុយមកបញ្ជាក់ទេនោះ ។ ភស្តុតាងផ្ទុយនេះអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

**មាត្រា ៤៣.-**

ចំពោះបទលហុ កំណត់ហេតុរបស់នគរបាលយុត្តិធម៌ ទុកជាបន្ទាល់ដរាបរហូតដល់មានភស្តុងាតផ្ទុយ ។ ល័ក្ខខ័ណ្ឌមានតែមួយទេគឺភ្នាក់ងារធ្វើកំណត់ហេតុត្រូវតែមានគុណសម្បត្តិដើម្បីពិនិត្យបទលហុនោះ ។

**មាត្រា ៤៤.-**

មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនក្នុងរយៈពេលដ៏ខ្លីបំផុតនូវកំណត់ហេតុរបស់ខ្លួនព្រមទាំងវត្ថុតាងភ្ជាប់ជាមួយផង ទៅរដ្ឋអាជ្ញាអមសាលាជំរះក្តីមានសមត្ថកិច្ច ។

**មាត្រា ៤៥.-**

មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធពិនិត្យបញ្ជាក់ផ្ទាល់នូវបទល្មើសព្រហ្មទណ្ឌទាំងឡាយ លើកលែងតែបទល្មើសខ្លះដែលច្បាប់តំរូវអោយមានពាក្យប្តឹងជាមុនដាច់ខាត ។

**មាត្រា ៤៦.-**

មន្ត្រីនគរបាលយុត្តិធម៌ក៏មានសិទ្ធិកត់ត្រាចំលើយសាក្សី និង មានសិទ្ធិឆែកឆេរលំនៅដ្ឋានផងដែរ ប៉ុន្តែសិទ្ធិឆែកឆេរលំនៅដ្ឋាននេះនឹងអាចធ្វើទៅបានកាលណាមានរឿងឧក្រិដ្ឋឬមជ្ឈិមជាក់ស្តែងតែប៉ុណោះ ។

**មាត្រា ៤៧.-**

មានតែក្នុងករណីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងប៉ុណ្ណោះទេ ទើបមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិចាប់ខ្លួនជនប្រព្រឹត្តបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំខ្លួនជនល្មើសក្នុងរយៈពេល ៤៨ម៉ោងយ៉ាងយូរ ទៅប្រគល់ជូនចៅក្រមមានសមត្ថកិច្ច ដោយមិនគិតដល់ពេលវេលាចាំបាច់សំរាប់បញ្ជូនជនល្មើសតាមមធ្យោបាយយ៉ាងឆាប់បំផុតដែលអាចធ្វើបាន ។

ក្នុងករណីមិនគោរពវិធានខាងលើនេះទេ នោះត្រូវទទួលការផ្តន្ទាទោសតាមមាត្រា ២២ និង មាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**មាត្រា ៤៨.-**

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ គ្មានសិទ្ធិតំកល់ទុកឥតចាត់ការនូវរឿងអាជ្ញាដែលខ្លួនបានទទួល ទោះមានការសំរុះសំរួលព្រមព្រៀងគ្នាហើយក៏ដោយ គឺត្រូវធ្វើកំណត់ហេតុបញ្ជូនទៅរដ្ឋអាជ្ញាមានសមត្ថកិច្ចជាដរាប ។

ករណីមិនគោរពវិធានខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលការផ្តន្ទាទោស ដែលមានចែងក្នុងមាត្រា ២២ និងមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ជំពូកទី ៣

## អំពីអយ្យការអមតុលាការខេត្ត-ក្រុង

**មាត្រា ៤៩.-**

នៅអមតុលាការខេត្ត-ក្រុងនីមួយៗមានអយ្យការមួយ ។ នៅអយ្យការនីមួយៗមានរដ្ឋអាជ្ញាម្នាក់ និងរដ្ឋអាជ្ញារង ។

**មាត្រា ៥០.-**

តាមគោលការណ៍រដ្ឋអាជ្ញាមានឋានន្តរសក្តិស្មើគ្នានឹងប្រធានតុលាការ ។

**មាត្រា ៥១.-**

តុលាការដែលជំនុំជំរះរឿងព្រហ្មទណ្ឌ ក៏ដូចរឿងក្តីឯទៀតដែរ នឹងទុកជាពេញលេញបានលុះត្រាតែមានតំណាងអយ្យការមួយរូបចូលរួម ។

**មាត្រា ៥២.-**

ចំពោះមុខសាលាជំរះក្តីផ្នែកព្រហ្មទណ្ឌ រដ្ឋអាជ្ញាត្រូវជា"គូក្តីដើមជានិច្ច" ។ ក្នុងន័យនេះរដ្ឋអាជ្ញាធ្វើបណ្តឹងអាជ្ញា ដោយចោទប្រកាន់ជនជាប់ចោទ និងសុំអោយអនុវត្តច្បាប់លើជននោះ ។

**មាត្រា ៥៣.-**

ចំពោះមុខសាលាជំរះក្តីផ្នែករដ្ឋប្បវេណី តំណាងអយ្យការគ្រាន់តែជា"គូក្តីរណប" គឺថា តំណាងអយ្យការអោយយោបល់របស់ខ្លួនបើយល់ឃើញថាជាការគួរ ។

តំណាងអយ្យការមិនអាចប្តឹងឧទ្ធរណ៍ ឬប្តឹងសាទុក្ខចំពោះសាលក្រមរដ្ឋប្បវេណី កាលណាខ្លួនគ្រាន់តែចូលជាគូក្តីរណប ។

**មាត្រា ៥៤.-**

ក្នុងរឿងរដ្ឋប្បវេណីមួយចំនួន ដែលប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍អនីតិជន ឬអសមត្ថជន....។ល។ តំណាងអយ្យការត្រូវតាំងខ្លួនជាគូក្តីដើម ។ ក្នុងករណីនេះអយ្យការចាត់ការដោយឯកឯង ។

**មាត្រា ៥៥.-**

បន្ទាប់ពីបានដឹងថា មានការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយភ្លាម រដ្ឋអាជ្ញាត្រូវចាត់ការខាងវិធានការស៊ើបអង្កេតដែលច្បាប់បានប្រគល់អោយខ្លួន ហើយដែលជាវិធានចាំបាច់ក្នុងការរកអោយឃើញនូវការពិត ។ ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលមានទំងន់ពិសេស រដ្ឋអាជ្ញាត្រូវជូនដំណឹងនេះភ្លាមទៅអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធមិ ។ រដ្ឋអាជ្ញាត្រូវចាត់ការតាមបង្គាប់ទាំងឡាយដែលខ្លួនបានទទួលពីអង្គការនេះអំពីបទល្មើសខាងលើ ។

ក្នុងករណីរដ្ឋអាជ្ញាមានធុរៈដោយមានជំងឺ ឬដោយមូលហេតុអ្វីផ្សេងទៀតនោះរដ្ឋអាជ្ញារងត្រូវចាត់ការជំនួស ។ ប្រសិនបើមានរដ្ឋអាជ្ញារងច្រើន រដ្ឋអាជ្ញារងដែលចាស់ជាងគេ ក្នុងបណ្តាសក្តិខ្ពស់ជាងគេត្រូវជំនួសរដ្ឋអាជ្ញា ។

ប្រសិនបើគ្មានរដ្ឋអាជ្ញារងទេ រដ្ឋមន្ត្រីក្រសួងយុត្តិធមិត្រូវចេញសេចក្តីសំរេចអោយចៅក្រមណាមួយនៅសាលាជំរះក្តីនោះ ទៅជំនួសរដ្ឋអាជ្ញាភ្លាម ។ ក្នុងករណីដែលមានការប្រញាប់បំផុត ប្រធានតុលាការនៃសាលា

ជំរះក្តីនេះ អាចចាត់តាំងចៅក្រមម្នាក់អោយជំនួសរដ្ឋអាជ្ញាជាបណ្តោះអាសន្នសិនបាន ហើយត្រូវជំរាបទៅរដ្ឋ-មន្ត្រីក្រសួងយុត្តិធមិភ្លាម ។

**មាត្រា ៥៦.-**

រដ្ឋអាជ្ញាមានបេសកកម្មត្រូវទទួលពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារទាក់ទងនឹងបទឧក្រិដ្ឋ ឬបទ-មជ្ឈិមណាមួយ ទោះជាពាក្យនោះចេញមកពីជនណាម្នាក់ ចេញមកពីមន្ត្រីនគរបាលយុត្តិធមិ ឬក៏ចេញពីមន្ត្រីឯទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌ ។

រដ្ឋអាជ្ញាមានបេសកកម្មផងដែរ :

-ទទួលកំណត់ហេតុធ្វើដោយមន្ត្រីនគរបាលយុត្តិធមិ ដែលពិនិត្យបញ្ជាក់បទឧក្រិដ្ឋ បទមជ្ឈិម ឬបទ-លហុ។

-ធ្វើដោយខ្លួនឯងនូវការស៊ើបអង្កេតបឋម បានតែក្នុងករណីបទឧក្រិដ្ឋ និងបទមជ្ឈិមជាក់ស្តែងប៉ុណ្ណោះទេ ។

-កេណ្ឌកំលាំងសាធារណៈដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

**មាត្រា ៥៧.-**

រដ្ឋអាជ្ញាគ្មានភារកិច្ចស្វែងរកជនប្រព្រឹត្តបទលហុទេ ប៉ុន្តែកាលណាតុលាការផ្នែកព្រហ្មទណ្ឌជំរះរឿងលហុ រដ្ឋអាជ្ញាអាចធ្វើការសន្និដ្ឋានអំពីទណ្ឌកម្ម ដែលត្រូវផ្តន្ទាទោសទៅលើបទលហុនោះបាន ។

**មាត្រា ៥៨.-**

នៅពេលដែលរដ្ឋអាជ្ញាទទួលពាក្យបណ្តឹងទាមទារ ពាក្យប្តឹងបរិហារ ឬកំណត់ហេតុណាមួយ រដ្ឋអាជ្ញាត្រូវចុះឬបង្គាប់អោយចុះពាក្យប្តឹង និងកំណត់ហេតុនោះក្នុងបញ្ជីមួយ ហៅថាបញ្ជី"ចុះបណ្តឹង"ជាបន្ទាន់ភ្លាម បញ្ជីនេះមានខ្ទង់ផ្សេងៗគឺ:

-ខ្ទង់ទីមួយមានលេខរៀងនៃរឿង ហើយនិងកាលបរិច្ឆេទនៃការចុះរឿងនោះក្នុងបញ្ជី

-ខ្ទង់ទីពីរ មានគោត្តនាម និងនាមនៃជនជាប់ចោទ

-ខ្ទង់ទីបី មានគោត្តនាម និងនាមនៃដើមបណ្តឹងប្រសិនបើមាន

-ខ្ទង់ទីបួន មានប្រភេទ កាលបរិច្ឆេទ និងទីកន្លែងនៃអំពើល្មើស

-ខ្ទង់ទីប្រាំ "ផ្សេងៗ"

**មាត្រា ៥៩.-**

លុះបានទទួលពាក្យប្តឹងទាមទារ ពាក្យប្តឹងបរិហារ ឬកំណត់ហេតុណាមួយហើយ បើខ្លួនឃើញថា អំពើ

ដែលគេប្តឹងផ្តល់មកនោះមិនចូលជាបទល្មើសព្រហ្មទណ្ឌទេ  រដ្ឋអាជ្ញាត្រូវសំរេចតំកល់រឿងនោះទុកឥតចាត់ការ ដោយចុះនិទ្ទេសនេះលើបណ្តឹង  ឬកំណត់ហេតុនោះព្រមទាំងលើបញ្ជីចុះបណ្តឹង  ។  ក្នុងករណីនេះ  រដ្ឋអាជ្ញាត្រូវអោយដំណឹងទៅដើមបណ្តឹង  អំពីសេចក្តីសំរេចរបស់ខ្លួន  ក្នុងរយៈពេលពីរខែយ៉ាងយូរ  ចាប់តាំងពីថ្ងៃទទួលពាក្យបណ្តឹង ។ ដើមបណ្តឹងមានសិទ្ធិប្តឹងតវ៉ា ចំពោះសេចក្តីសំរេចនេះទៅសាលាឧទ្ធរណ៍ ។

សេចក្តីសំរេចតំកល់រឿងទុកមិនចាត់ការរបស់រដ្ឋអាជ្ញានេះ គ្មានអាជ្ញាជាសេចក្តីសំរេចដាច់ខាតនៅឡើយទេ  មានន័យថា  រដ្ឋអាជ្ញាអាចប្រែប្រួលសេចក្តីសំរេចនេះបានជាដរាប  កុំអោយតែបណ្តឹងអាជ្ញាត្រូវរលត់  ដោយផុតអាជ្ញាយុកាល ឬដោយករណីផ្សេងទៀត ដែលមានចែងក្នុងច្បាប់ ។

**មាត្រា  ៦០.-**

កាលបើអំពើដែលគេប្តឹងមកនោះជាបទឧក្រិដ្ឋ  ឬមជ្ឈិម  រដ្ឋអាជ្ញាស្នើសុំការស៊ើបអង្កេតភ្លាម  មានន័យថា  រដ្ឋអាជ្ញាធ្វើដីកាសន្និដ្ឋានមួយហៅថា  ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ  ហើយបញ្ជូនដីកានេះទៅអោយចៅក្រម  ដោយវាយតំលៃអំពីបទល្មើស  បញ្ជាក់អំពីអត្ថបទច្បាប់  និងដោយចង្អុលអោយចំជនប្រព្រឹត្តបទល្មើស ។

**មាត្រា  ៦១.-**

ក្នុងករណីបទល្មើសមជ្ឈិមរដ្ឋអាជ្ញាអាច   ឬមួយចោទប្រកាន់ជនល្មើសហើយបញ្ជូនផ្ទាល់ទៅតុលាការព្រហ្មទណ្ឌដើម្បីជំនុំជំរះ ឬមួយចាត់ការដូចមានចែងក្នុងមាត្រា ៦០ ខាងលើនេះ ។

រដ្ឋអាជ្ញាចោទប្រកាន់  និងបញ្ជូនជនល្មើសផ្ទាល់ទៅតុលាការ  ដើម្បីជំនុំជំរះបាននោះ  កាលខ្លួនឃើញថាសំណុំរឿងមូលសព្វគ្រប់ហើយ ហើយបទល្មើសមានធាតុផ្សំគ្រប់គាន់ ។

រដ្ឋអាជ្ញាមានសិទ្ធិផងដែរសួរយកពត៌មានបន្ថែម  មុននឹងបញ្ជូនរឿងទៅតុលាការ  ។ ចំពោះករណីនេះរដ្ឋអាជ្ញាអាចបញ្ជាអោយមន្ត្រីនគរបាលយុត្តិធម៌ផ្តល់អោយខ្លួននូវពត៌មានចាំបាច់ទាំងឡាយ  ។  លុះបានទទួលពត៌មានសព្វគ្រប់ហើយទើបរដ្ឋអាជ្ញាបញ្ជូនសំណុំរឿងទៅសាលាជំរះក្តីដើម្បីជំនុំជំរះ ដោយមានមូលដ្ឋានច្បាស់លាស់

**មាត្រា  ៦២.-**

ក្នុងករណីដែលមានបទឧក្រិដ្ឋជាក់ស្តែងកើតឡើងហើយប្រសិនបើចៅក្រមស៊ើបអង្កេតពុំទាន់បានទទួលរឿងនៅឡើយទេ នោះរដ្ឋអាជ្ញាអាចចេញដីកានាំខ្លួនជនដែលសង្ស័យបាន ។

រដ្ឋអាជ្ញាត្រូវសួរយកចំលើយពីជននោះភ្លាម  ។  ប្រសិនបើជននោះ  មានអ្នកការពារសិទ្ធិអមមកជាមួយផង រដ្ឋអាជ្ញាត្រូវសួរជននោះនៅចំពោះមុខអ្នកការពារសិទ្ធិរបស់គេ ។ រដ្ឋអាជ្ញាអាចសួរយកចំលើយសាក្សី ដែល

មានវត្តមាននៅទីនោះ និងចេញដីកាចាត់វិធានការបណ្ដោះអាសន្នទាំងឡាយដើម្បីធានារក្សាអោយបាននូវមុខសញ្ញាភស្តុតាងទាំងឡាយ ។

រដ្ឋអាជ្ញាចូលពិនិត្យក្នុងផ្ទះនៃឧក្រិដ្ឋជន ហើយធ្វើការរឹបអូសនូវភស្តុតាងទាំងឡាយចាំបាច់សំរាប់បំភ្លឺការពិត ។

រដ្ឋអាជ្ញាអាចសួរយកចំលើយពីជនទាំងឡាយ ដែលបានផ្ដល់ពត៌មានមានប្រយោជន៍ ប៉ុន្តែមិនអាចបង្គាប់អោយគេហៅសាក្សី ឬបញ្ជាអោយអ្នកដែលខ្លួនសួរនោះស្បថឡើយ ។ រដ្ឋអាជ្ញាមានសិទ្ធិស្នើអោយអ្នកបច្ចេកទេសវាយតំលៃលើវត្ថុតាងអ្វីមួយ ដែលរដ្ឋអាជ្ញាយល់ឃើញថាចាំបាច់ ។

រដ្ឋអាជ្ញាមានសិទ្ធិហាមមិនអោយជនទាំងឡាយចេញពីកន្លែងកើតហេតុ ។ បើមិនគោរពបំរាមនេះទេ រដ្ឋអាជ្ញាអាចចេញអាជ្ញាឃាត់ជននោះ ២៤ ម៉ោងបាន ។

ក្រោយពីបានធ្វើកំណត់ហេតុរបស់ខ្លួនចប់ ស្ដីពីការចុះដល់ទីកន្លែងនោះ រដ្ឋអាជ្ញាត្រូវបញ្ជូនជាប្រញាប់នូវសំណុំរឿងព្រមទាំងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រម ដែលនឹងធ្វើការស៊ើបសួរបន្ថែម និងធ្វើវាល់លិខិតឯកសារឡើងវិញ កាលបើចៅក្រមនេះយល់ឃើញថានៅមានខ្វះចន្លោះ ។

កាលណាចៅក្រមស៊ើបអង្កេតបានទទួលរឿង ហើយមានវត្តមាននៅនឹងកន្លែងកើតហេតុនោះ រដ្ឋអាជ្ញាក្ដី មន្ត្រីនគរបាលយុត្តិធម៌ក្ដីត្រូវប្រគល់ការងារស៊ើបអង្កេតទាំងស្រុងជូនចៅក្រម ។

**មាត្រា ៦៣.-**

ប្រសិនបើជនល្មើសត្រូវបានចាប់ខ្លួនជាមុនដោយមានកំណត់ហេតុត្រឹមត្រូវ ហើយត្រូវបាននាំខ្លួនទៅជូនរដ្ឋអាជ្ញា រដ្ឋអាជ្ញាត្រូវពិនិត្យមើលជាបន្ទាន់ភាមថា តើអំពើដែលគេដាក់បន្ទុកទៅលើជននោះមានគ្រប់គ្រាន់ហើយឬនៅ ។ ប្រសិនបើអំពើប្រព្រឹត្តនោះ ជាអំពើប្រព្រឹត្តជាក់ស្ដែង ហើយអំពើនោះចូលជាបទល្មើសព្រហ្ម-ទណ្ឌដែលត្រូវផ្ដន្ទាទោសដាក់គុក រដ្ឋអាជ្ញាសួរយកចំលើយពីជនល្មើស សួរជាអាទិ៍ :

-អត្តសញ្ញាណគោត្តនាម និងនាម អាយុ វិជ្ជាជីវៈ និងទីលំនៅ ទីកន្លែង និងកាលបរិច្ឆេទនៃកំណើតរបស់ជនល្មើស ។

-គោត្តនាម និងនាមរបស់ឪពុក-ម្ដាយនៃជនល្មើស ។

-ប្រវត្តិរូបសង្ខេប ស្ដីពីពតិមានថា តើជននោះធ្លាប់មានទោសពីមុនមកដែរឬទេ ។ បន្ទាប់មករដ្ឋអាជ្ញាសួរយកចំលើយអំពី :

-បទល្មើសដែលជាបន្ទុកទៅលើជនល្មើស

-កាលៈទេសៈទាំងឡាយទាក់ទងនឹងបទល្មើស

រដ្ឋអាជ្ញាត្រូវធ្វើកំណត់ហេតុ ហើយចុះហត្ថលេខាជាមួយក្រឡាបញ្ជីម្នាក់ដែលជាអ្នកសរសេរកំណត់ហេតុនោះ ។កំណត់ហេតុនេះក៏ត្រូវអោយមានជនល្មើសចុះហត្ថលេខាដែរ ប្រសិនបើជនល្មើសមិនចេះចុះហត្ថលេខាត្រូវចុះ និងនិទ្ទេសក្នុងកំណត់ហេតុ ហើយអោយជនល្មើសផ្តិតមេដៃជាសំគាល់ ។

**មាត្រា ៦៤.-**

កាលបើបានទទួលសំណុំរឿងបទល្មើសមជ្ឈិមហើយ ចៅក្រមជំនុំជំរះសំរេចអំពីការឃុំខ្លួនបណ្តោះអាសន្ន និងបង្គាប់អោយនាំខ្លួនជនជាប់ចោទមកជុំនុំជំរះនាសវនាការខាងមុខភ្លាម ។ ប្រសិនបើចៅក្រមឃើញថាសំណុំរឿងមិនទាន់មូលគ្រប់គ្រាន់ទេ ចៅក្រមជំនុំជុំរះអាចលើយករឿងនោះទៅជំនុំជំរះនៅពេលក្រោយបាន កុំអោយតែហួសរយៈកាលបួនខែគិតពីថ្ងៃឃុំខ្លួន ។

**មាត្រា ៦៥.-**

ប្រសិនបើចៅក្រមជុំនុំជំរះឃើញថា ជនជាប់ចោទអាចអនុញ្ញាតអោយនៅក្រៅឃុំជាបណ្តោះអាសន្នបាន ដោយអោយដាក់ប្រាក់ធានា ឬក៏មិនបាចដាក់ប្រាក់ធានា ចៅក្រមជុំនុំជំរះសំរេចអំពីបញ្ហានេះមុនពិនិត្យដល់អង្គសេចក្តី ។ ចៅក្រមជុំនុំជំរះអាចសំរេចអំពីបញ្ហានេះបានដែរ កាលណាជនជាប់ចោទបានសុំជាលាយលក្ខណ៏អក្សរ ។

**មាត្រា ៦៦.-**

ប្រសិនបើចៅក្រមជុំនុំជំរះឃើញថា អំពើដែលបញ្ជូនមកអោយខ្លួននោះ ពុំមែនចូលជាបទល្មើសមជ្ឈិមជាក់ស្តែងដូចការចោទប្រកាន់ទេ ចៅក្រមជុំនុំជំរះបដិសេធនីតិវិធីនេះ ហើយបញ្ជូនសំណុំរឿងត្រឡប់មកអយ្យការវិញ ដើម្បីចាត់ការតាមច្បាប់ ។រដ្ឋអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ហើយបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេត ដែលត្រូវចាត់ការបន្តទៀតតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៦៧.-**

រដ្ឋអាជ្ញានឹងអាចប្រើនីតិវិធីចោទប្រកាន់ផ្ទាល់ទៅតុលាការតែម្តងនោះបាន តែក្នុងករណីដែលជនជាប់ចោទ អាចនឹងត្រូវផ្តន្ទាទោសដាក់គុក ដែលអតិបរមានៃទោសមិនលើសពី ១ឆ្នាំ បើពុំនោះទេរដ្ឋអាជ្ញាត្រូវបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេតសិន ។

## ជំពូកទី ៤

## អំពីចៅក្រមស៊ើបអង្កេត

**មាត្រា ៦៨.-**

នៅក្នុងតុលាការខេត្ត-ក្រុងនីមួយៗ មានចៅក្រមមួយរូប ឬច្រើនរូបទទួលការងារស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌទៅតាមទំហំការងារ និងសេចក្តីត្រូវការរបស់តុលាការ ។

ចៅក្រមណា ដែលទទួលស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌណាមួយហើយ ពុំអាចចូលរួមជំនុំជំរះរឿង ដែលខ្លួនបានទទួលភារកិច្ចស៊ើបអង្កេតនោះឡើយ ។

**មាត្រា ៦៩.-**

ចៅក្រមស៊ើបអង្កេត ធ្វើលិខិតស៊ើបអង្កេតអ្វីមិនបាននោះទេ ប្រសិនណាបើគ្មានបានទទួលដីកា សន្និដ្ឋាន បញ្ជូនរឿងស៊ើបសួររបស់តំណាងអយ្យការទេ ។

ក្នុងករណីដែលចៅក្រមស៊ើបអង្កេតបានទទួលផ្ទាល់នូវបណ្តឹងទាមទារណាមួយនោះ ចៅក្រមស៊ើប-អង្កេត ត្រូវបញ្ជូនពាក្យបណ្តឹងនោះ ព្រមទាំងលិខិតនានាដែលមានភ្ជាប់មកជាមួយ ដោយខ្លួនមិនត្រូវការស៊ើប អង្កេតអ្វីបន្តិចបន្តួចមុនឡើយ ទៅជូនរដ្ឋអាជ្ញាដែលនឹងត្រូវចាត់ការដូចបញ្ញត្តិដែលមានចែងក្នុងជំពូកមុន ។

**មាត្រា ៧០.-**

ចៅក្រមស៊ើបអង្កេតទទួលចាត់ការតាមការចោទប្រកាន់ទៅលើអំពើណាមួយ ដែលបានបញ្ជាក់ច្បាស់ លាស់ ។ ដូចនេះ ចៅក្រមស៊ើបអង្កេតត្រូវស៊ើបសួរបានតែក្នុងអំពើព្រហ្មទណ្ឌ ដែលមានកំណត់ក្នុងដីកាសន្និដ្ឋាន បញ្ជូនអោយស៊ើបសួររបស់តំណាងអយ្យការ ។

**មាត្រា ៧១.-**

ក្នុងពេលកំពុងស៊ើបសួរ បើមានអំពើជាបទមជ្ឈិមមួយទៀតលេចឡើង ចៅក្រមស៊ើបអង្កេតត្រូវតែមាន ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរថ្មីមួយទៀត ទើបខ្លួនចាត់ការស៊ើបអង្កេតរឿងមជ្ឈិមថ្មីនេះបាន ។

ប្រសិនបើអំពើថ្មីនោះ គ្រាន់តែជាស្ថានទំងន់នៃអំពើដែលខ្លួនបានទទួលស៊ើបសួរពីមុននោះទេ ចៅក្រម ស៊ើបអង្កេតមិនបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរថ្មីទៀតឡើយ ។

**មាត្រា ៧២.-**

ចៅក្រមស៊ើបអង្កេតមានសិទ្ធិទៅពិនិត្យដល់កន្លែង ដែលបទល្មើសព្រហ្មទណ្ឌកើតមាន ហើយមាន ក្រឡាបញ្ជីម្នាក់ទៅជាមួយផង ។ ក្នុងករណីនេះ ត្រូវអោយដំណឹងទៅរដ្ឋអាជ្ញាអំពីការចេញដំណើរនេះ ។

**មាត្រា ៧៣.-**

កាលបើអំពើដែលចៅក្រមបានទទួលស៊ើបសួរនោះគ្មានលក្ខណៈជាបទមជ្ឈិម ហើយគ្រាន់តែចូលជាបទ លហុប៉ុណ្ណោះ ចៅក្រមស៊ើបអង្កេតបន្តការស៊ើបសួរនោះទៅទៀតរួចបញ្ជូនសំនុំរឿងទៅតុលាការ ។

**មាត្រា ៧៤.-**

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបអង្កេតច្រើនរូបនៅមណ្ឌលខុសគ្នា ហើយទទួលបណ្តឹងទាំង

អស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះដោយឥតបើកការតវ៉ា ។

**មាត្រា ៧៥.-**

នៅពេលជនជាប់ចោទចូលខ្លួនជាលើកដំបូង ចៅក្រមស៊ើបអង្កេតត្រូវសួរកត់ត្រាអំពីអត្តសញ្ញាណរបស់ជននោះ ប្រាប់អំពីអំពើដែលចោទប្រកាន់ទៅលើជននោះ ហើយទទួលការរាយការណ៍បន្ទាប់ពីបានប្រាប់ជននោះអំពីសិទ្ធិរបស់ខ្លួនដែលអាចឆ្លើយ ឬមិនទាន់ឆ្លើយដោយគ្មានមេធាវី ឬអ្នកការពារសិទ្ធិដែលខ្លួនជ្រើសរើស ឬដែលត្រូវតែងតាំងដោយឯកឯង ។

**មាត្រា ៧៦.-**

នៅពេលចូលខ្លួនជាលើកដំបូងនេះ ក្រោយពីបានបញ្ជាក់អំពីអត្តសញ្ញាណ និងក្រោយពីបានទទួលដំណឹងអំពីអំពើដែលខ្លួនត្រូវជាប់ចោទប្រកាន់ប្រសិនបើជនជាប់ចោទជំរាបចៅក្រមអង្កេតថា :

ខ្លួនសុំជ្រើសរើសមេធាវីមួយ ឬថាខ្លួនសុំអោយរដ្ឋចាត់តាំងមេធាវីមួយដើម្បីការពារខ្លួន នោះចៅក្រមស៊ើបអង្កេតត្រូវផ្អាកការសួរយកចំលើយសិន ហើយត្រូវហៅក្នុងរយៈពេលដ៏ខ្លីជាទីបំផុត នូវមេធាវីនោះមកស្តាប់ការសួរយកចំលើយលើជនជាប់ចោទដែលនឹងធ្វើនៅចំពោះមុខមេធាវីនោះ ។

ការចាត់តាំងដោយឯកឯងនូវមេធាវី ត្រូវធ្វើដោយប្រធានតុលាការក្នុងករណីដូចតទៅ :

-ជនរងគ្រោះជាអនីតិជនគ្មានទីពឹង

-ជនជាប់ចោទជាអនីតិជនគ្មានទីពឹង

-ជនជាប់ចោទជាមនុស្ស គ ថ្លង់ មនុស្សខ្វាក់ ឬជនមានវិបត្តិស្មារតី

-ជនជាប់ចោទត្រូវជាប់ចោទពីបទប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ហើយខ្លួនគ្មានលទ្ធភាពអាចពឹងអ្នកជួយការពារខ្លួនបាន ។

ក្នុងករណីផ្សេងពីករណីដូចមានលើកខាងលើនេះចៅក្រមស៊ើបអង្កេតអាចសួរយកចំលើយជនជាប់ចោទបាន កាលណាជននេះសុខចិត្តការពារខ្លួនដោយខ្លួនឯង ។

**មាត្រា ៧៧.-**

ប្រសិនបើមេធាវី ឬអ្នកការពារសិទ្ធិមិនចូលខ្លួនមកតាមថ្ងៃ និងម៉ោងដូចបានណាត់ទេ ចៅក្រមស៊ើបអង្កេតមានសិទ្ធិសួរយកចំលើយដោយមិនបាច់មានវត្តមាននៃមេធាវី ។ ចៅក្រមស៊ើបអង្កេត ត្រូវកត់ជានិទ្ទេសអំពីអវត្តមាននេះ ក្នុងកំណត់ហេតុសួរចំលើយ ។

**មាត្រា ៧៨.-**

សំណុំរឿងត្រូវទុកអោយមេធាវី ឬអ្នកការពារសិទ្ធិពិនិត្យមើលបានរាល់ពេលវេលា ។ ការជូនសំណុំរឿងអោយមើលនេះ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជី ឬធ្វើនៅក្នុងបន្ទប់របស់ចៅក្រមស៊ើបអង្កេត បើទីកន្លែងនោះអាចទទួលអោយធ្វើបាន ។

មេធាវី ឬអ្នកការពារសិទ្ធិអាចត្រូវបានអនុញ្ញាតឱ្យប្រើស្មៀនរបស់ខ្លួនដោយមកចំលងឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងក្រោមការទទួលខុសត្រូវរបស់ខ្លួនទាំងស្រុង ។

**មាត្រា ៧៩.-**

បន្ទាប់ពីជនជាប់ចោទចូលខ្លួនជាលើកដំបូង ចៅក្រមស៊ើបអង្កេតមានសិទ្ធិសំរេចថា ត្រូវអោយជនជាប់ចោទនៅក្រៅឃុំឬត្រូវឃុំខ្លួនជាបណ្តោះអាសន្ន ។ សេចក្តីសំរេចនេះមានប្រសិទ្ធភាពអនុវត្តភ្លាម ទោះជាមានការប្តឹងតវ៉ាក៏ដោយ លើកលែងតែមានបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ។

ភាគីទាំងពីរមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសំរេចខាងលើនេះក្នុងរយៈពេល ១៥ ថ្ងៃគត់គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសំរេចបដិសេធបណ្តឹងរបស់ខ្លួន ។

សាលាឧទ្ធរណ៍ត្រូវសំរេចរឿងនេះក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ៨០.-**

ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួន ហើយជននេះមានមេធាវី ឬអ្នកការពារសិទ្ធិអោយខ្លួន មេធាវី ឬអ្នកការពារសិទ្ធិអាចប្រាស្រ័យទាក់ទងបានដោយសេរីជាមួយនឹងកូនក្តីរបស់ខ្លួន ។

ការនិយាយទាក់ទងគ្នារវាងមេធាវី ឬអ្នកការពារសិទ្ធិជាមួយកូនក្តីឃុំខ្លួន មិនត្រូវបានគេលួចស្តាប់ ឬកត់ត្រាឡើយ ។ មេធាវីឬអ្នកការពារសិទ្ធិអាចអោយកូនក្តីរបស់ខ្លួនស្តាប់នូវឯកសារទាំងឡាយដែលខ្លួនបានឃើញ ឬបានកត់ត្រាចេញពីសំណុំរឿង ហើយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ក្នុងកិច្ចការពារកូនក្តីនោះ ។ ប៉ុន្តែមេធាវីមិនត្រូវប្រគល់ឯកសារ ឬវត្ថុអ្វីឱ្យដល់កូនក្តីខ្លួនឡើយ កាលបើគ្មានការអនុញ្ញាតពិសេសពីចៅក្រមស៊ើបអង្កេត ។

**មាត្រា ៨១.-**

ចៅក្រមស៊ើបអង្កេត បង្គាប់អោយកោះហៅចូលមកចំពោះមុខខ្លួននូវជនទាំងឡាយដែលមានឈ្មោះនៅក្នុងពាក្យប្តឹងទាមទារ ឬពាក្យប្តឹងបរិហារ សាក្សីទាំងឡាយដែលជនជាប់ចោទសំអាង ព្រមទាំងជនទាំងអស់ដែលខ្លួនយល់ឃើញថា ចំលើយរបស់ជនទាំងនោះនឹងមានប្រយោជន៍ក្នុងការបំភ្លឺការពិត ។

ក្នុងគ្រប់ករណីទាំងអស់ ចៅក្រមស៊ើបអង្កេតមានសិទ្ធិសួរតទល់គ្នារវាងភាគី និងភាគី ឬរវាងសាក្សី និងសាក្សីក៏បាន ឬរវាងសាក្សី និងភាគីក៏បាន ។

**មាត្រា ៨២.៊**

សាក្សីមុននឹងចូលឆ្លើយ ត្រូវធ្វើសច្ចាប្រណិធានត្រឹមត្រូវតាមសាសនា ឬជំនឿរបស់ខ្លួន ។ សាក្សីត្រូវបានសួរយកចំលើយ ម្នាក់ម្តងៗផ្សេងពីគ្នា ។ ជនជាប់ចោទនឹងត្រូវនាំមកចំពោះមុខសាក្សីបាន កាលណាចៅក្រមយល់ឃើញថា ការសួរតទល់តំរូវអោយមាន ។

**មាត្រា ៨៣.៊**

កំណត់ហេតុយកចំលើយសាក្សីត្រូវបានចុះហត្ថលេខាដោយចៅក្រម ក្រឡាបញ្ជី និង សាក្សី ក្រោយពីបានអានកំណត់ហេតុអោយសាក្សីនោះស្តាប់។ ប្រសិនបើសាក្សីនោះមិនព្រមចុះហត្ថលេខា នោះត្រូវធ្វើនិទ្ទេសនៃការមិនយល់ព្រមនោះ ។ ទំព័រនីមួយៗនៃកំណត់ហេតុយកចំលើយ ត្រូវចុះហត្ថលេខាដោយចៅក្រម ក្រឡាបញ្ជី និងសាក្សី ។

ការសរសេរមិនត្រូវទុកអោយមានចន្លោះបន្ទាត់ទំនេរទេ ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវតែមានសេចក្តីបញ្ជាក់ និងមានហត្ថលេខារបស់ចៅក្រម ក្រឡាបញ្ជី និងសាក្សី ។ ចំពោះការយកចំលើយអ្នកឯទៀតក្នុងសំណុំរឿង ក៏ត្រូវធ្វើដូចខាងលើនេះដែរ ។

**មាត្រា ៨៤:**

ជនទាំងឡាយដែលត្រូវបានអញ្ជើញមកឆ្លើយជាសាក្សីត្រូវតែចូលមកឆ្លើយ តាមបំណងនៃការអញ្ជើញ ។

ក្រោយពីបានទទួលលិខិតអញ្ជើញហើយ សាក្សីមិនចូលមកចំពោះមុខចៅក្រម នោះចៅក្រមអាចចេញដីកាអោយនាំខ្លួនសាក្សីនោះ ។

**មាត្រា ៨៥.៊**

ក្នុងករណីដែលមានការចាំបាច់ជាដាច់ខាត បើសាក្សីឈឺ ឬមិនអាចនឹងធ្វេដំណើរបាន ចៅក្រមដោយមានក្រឡាបញ្ជីអមផងអាចអញ្ជើញទៅកាន់ទីលំនៅសាក្សីបាន ដើម្បីស្តាប់ហើយកត់យកចំលើយរបស់សាក្សីនេះ ។

**មាត្រា ៨៦.៊**

បើសាក្សីមានលំនៅនៅក្នុងខេត្ត ឬក្រុងដទៃពីខេត្ត-ក្រុងនៃតុលាការរបស់ខ្លួន ចៅក្រមស៊ើបអង្កេតអាចចេញដីកាផ្ទេរសមត្ថកិច្ចមួយឱ្យទៅចៅក្រមនៃខេត្ត ឬក្រុងដែលជននោះស្នាក់នៅ ដើម្បីសួរ និងកត់យកចំលើយរបស់សាក្សីនោះ ។

**មាត្រា ៨៧.៊**

ក្រៅពីការស្តាប់ និងយកចំលើយសាក្សី ចៅក្រមស៊ើបអង្កេតអាចចាត់តាំងវិធានការផ្សេងៗទៀតបាន

អោយតែវិធានការនោះមានប្រយោជន៍ដល់ការបញ្ជាក់ការពិត ។ ឧទាហរណ៍- ដូចជាចៅក្រមស៊ើបអង្កេត ត្រូវចុះទៅកាន់ទីលំនៅរបស់ជនជាប់ចោទដើម្បីធ្វើការឆែកឆេរលំនៅដ្ឋាននោះ ។ ក្នុងករណីនេះមេធាវី ឬអ្នកការពារសិទ្ធិជនជាប់ចោទត្រូវបានអោយដំណឹង និងអញ្ជើញអោយចុះទៅជាមួយចៅក្រមដែរ ។

ចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុរៀបរាប់សេចក្តីអោយពិស្តារអំពីកិច្ចប្រតិបត្តិការ ដែលខ្លួនបានធ្វើ ហើយត្រូវចុះហត្ថលេខាជាមួយក្រឡាបញ្ជី និងជនទាំងអស់ដែលបានចូលរួមក្នុងការឆែកឆេរនោះ ។

ចៅក្រមត្រូវធ្វើផងដែរនូវបញ្ជីសារពើភ័ណ្ឌច្បាស់លាស់ និងពិស្តារនៃវត្ថុ និងលិខិតដែលខ្លួនបានរឹបអូស ហើយទុកវត្ថុ និងលិខិតទាំងនោះក្នុងកញ្ចប់បិទជិត ហើយបោះត្រានៅលើកញ្ចប់នោះព្រមទាំងបានចុះហត្ថលេខាចៅក្រម និងក្រឡាបញ្ជីផង ។

**មាត្រា ៨៨.-**

ចៅក្រមស៊ើបអង្កេតអាចចាត់អោយធ្វើកោសលវិច្ច័យ កាលណាខ្លួនយល់ថា វិធានការនេះចាំបាច់ដើម្បីបញ្ជាក់ការពិត។ ក្នុងករណីនេះ ចៅក្រមស៊ើបអង្កេតត្រូវទៅរកជនដែលខ្លួនយល់ថា អាចធ្វើមូលវិចារបានអំពីធាតុ និងកាលៈទេសៈទាំងឡាយនៃបទល្មើស ដូចជាគ្រូពេទ្យ អ្នកជំនាញគណនេយ្យ ជាងមាស... ។ល។

បើជាមរណភាពមួយមិនដឹងជាបណ្តាលមកពីមូលហេតុអ្វី ចៅក្រមស៊ើបអង្កេតត្រូវរកគ្រូពេទ្យឯកទេសអោយវាយតំលៃមូលហេតុនៃមរណៈភាពនេះ។

ចំណាយផ្សេងៗក្នុងកោសល្យវិច្ច័យ ត្រូវបញ្ចូលទៅជាមួយប្រាក់ប្រដាប់ក្តី ហើយដាក់ទៅក្នុងបន្ទុកអ្នកជាប់ចោទ កាលបើអ្នកជាប់ចោទនោះត្រូវផ្តន្ទាទោសជាស្ថាពរនៅពេលខាងមុខ។ បើជនជាប់ចោទត្រូវបានរួចខ្លួនប្រាក់ចំណាយក្នុងកោសលវិច្ច័យត្រូវនៅក្នុងបន្ទុករបស់រដ្ឋ។

ចៅក្រមស៊ើបអង្កេតអាចចាត់អោយធ្វើប្រតិកោសល្យវិច្ច័យបាន កាលណាខ្លួនយល់ឃើញថាចាំបាច់។

**មាត្រា ៨៩.-**

កាលណាចៅក្រមស៊ើបអង្កេតយល់ថា ការប្រមូលពតិមានរបស់ខ្លួនចប់ហើយ សំណុំរឿងត្រូវទុកអោយមេធាវីនៃជនជាប់ចោទពិនិត្យ តាមត្រូវការក្នុងរយៈពេល ២៤ ម៉ោង។ បន្ទាប់មកចៅក្រមនេះ ត្រូវចេញដីកាជូនរឿងទៅពិនិត្យ។ ដូចនេះត្រូវបញ្ជូនសំណុំរឿងទៅរដ្ឋអាជ្ញា។

ក្នុងរយៈពេល ៣ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿងរដ្ឋអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរហើយប្តឹងទៅចៅក្រមស៊ើបអង្កេតវិញ។

**មាត្រា ៩០.-**

កាលបើចៅក្រមស៊ើបអង្កេតយល់ឃើញថា ហេតុការណ៍ដែលកើតមានមិនចូលជាបទឧក្រិដ្ឋ បទមជ្ឈិម

ឬបទលហុ ឬក៏គ្មានបន្ទុកគ្រប់គ្រាន់ទៅលើជនល្មើសអំពីបទចោទនោះ ចៅក្រមស៊ើបអង្កេតមានសិទ្ធិសំរេចចេញដីកាលើកលែងចោទប្រកាន់។ តាមគោលការណ៍ដីការបស់ចៅក្រមស៊ើបអង្កេត ត្រូវលើកមូលហេតុនៃការសំរេចរបស់ខ្លួន។

ដីកានេះត្រូវជូនទៅរដ្ឋអាជ្ញាភ្លាម ព្រមទាំងសំណុំរឿងដើម្បីអោយរដ្ឋអាជ្ញាប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល ២៤ ម៉ោង។បើសិនមានបណ្តឹងតវ៉ាពីរដ្ឋអាជ្ញា នោះជនជាប់ចោទជាប់ឃុំឃាំង ត្រូវនៅជាប់ឃុំឃាំងដដែល។ ផ្ទុយទៅវិញ បើគ្មានការតវ៉ារបស់រដ្ឋអាជ្ញាទេនោះ ចៅក្រមស៊ើបអង្កេតចេញដីកាដោះលែងជនជាប់ចោទ ប្រសិនបើជននេះគ្មានត្រូវជាប់ឃុំពីមូលហេតុអ្វីផ្សេងទៀតនោះ។

**មាត្រា ៩១.-**

ប្រសិនបើមានដើមបណ្តឹងរដ្ឋប្បវេណី ដីកាលើកលែងការចោទប្រកាន់ ដែលមានការឯកភាពពីរដ្ឋអាជ្ញាផងនោះ ត្រូវជូនជាដំណឹងដល់ភាគីដើមបណ្តឹងនោះ។ក្នុងរយៈពេល៦០ថ្ងៃ គិតពីថ្ងៃទទួលដំណឹងរដ្ឋប្បវេណីមានសិទ្ធិតវ៉ាទៅសាលាឧទ្ធរណ៍។

ប្រសិនបើសាលាឧទ្ធរណ៍បដិសេធដីកាលើកលែងចោទ ប្រធានសាលាឧទ្ធរណ៍ អាចចេញដីការកចាប់ខ្លួនជនជាប់ចោទជាថ្មី ហើយយកមកឃុំខ្លួនបណ្តោះអាសន្នបាន កាលណាជនជាប់ចោទនៅក្រៅឃុំ។

**មាត្រា ៩២.-**

ប្រសិនបើបទល្មើសត្រូវបានរកទៅឃើញថា ត្រូវផ្តន្ទាទោសមជ្ឈិម ឬឧក្រិដ្ឋ ចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនជនជាប់ចោទទៅតុលាការខេត្ត-ក្រុង ក្រោយពីបានទទួលការសន្និដ្ឋានពីរដ្ឋអាជ្ញា។

ចៅក្រមស៊ើបអង្កេតមានសេរីភាពពេញទីក្នុងការវាយតំលៃកំណត់បទល្មើស ទៅលើអំពើល្មើសដែលបានប្រព្រឹត្ត។ បើសិនជាចៅក្រមនេះយល់ថា ត្រូវកែប្រែបទល្មើសខុសពីការសន្និដ្ឋានរបស់រដ្ឋអាជ្ញា ចៅក្រមស៊ើបអង្កេតត្រូវបញ្ជាក់អោយបានច្បាស់លាស់ក្នុងដីកាបញ្ជូនរឿងរបស់ខ្លួននូវមូលហេតុនៃការកែប្រែនេះ។

ក្នុងករណីនេះ ដីកាកែប្រែបទល្មើសនោះត្រូវជូនទោរដ្ឋអាជ្ញាដែលមានសិទ្ធិប្តឹងតវ៉ាក្នុង ៤៥ ម៉ោងទៅសាលាឧទ្ធរណ៍ ។

**មាត្រា ៩៣.-**

ក្នុងករណីកែប្រែបទល្មើសពីបទមជ្ឈិមទៅបទឧក្រិដ្ឋ នោះចាំបាច់ទាមទារអោយមានការចោទប្រកាន់ថ្មីនិង ការសួរចំលើយថ្មីទៅលើជនជាប់ចោទពីបទឧក្រិដ្ឋនេះ ។

**មាត្រា ៩៤.-**

ក្នុងគ្រប់ករណី រដ្ឋអាជ្ញាអាចប្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសំរេចរបស់ចៅក្រមស៊ើបអង្កេតកាលណាខ្លួន

មិនសុខចិត្តនឹងសេចក្តសំរេចនេះ ។

**មាត្រា ៩៥.-**

កាលណាមានពាក្យបណ្តឹង របស់ដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងអោយឃុំខ្លួនជនជាប់ចោទ ដែលនៅក្រៅឃុំនោះ ចៅក្រមស៊ើបអង្កេតត្រូវសំរេចអំពីបញ្ហានេះក្នុងរយៈពេល៥ថ្ងៃ ហើយជូនដំណឹងទៅម្ចាស់បណ្តឹងវិញអំពីសេចក្តីសំរេចរបស់ខ្លួន ។ ម្ចាស់បណ្តឹងក្នុងករណីមិនសុខចិត្តនឹងសេចក្តីសំរេចនេះ មានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៏ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។

## ជំពូកទី ៥

## តុលាការ ខេត្ត-ក្រុង

**មាត្រា ៩៦.-**

នៅខេត្តឬក្រុងនីមួយមានតុលាការមួយដែលមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្ត ឬក្រុងនោះ ។

ក្នុងនាមជា"តុលាការផ្នែកព្រហ្មទណ្ឌ"តុលាការខេត្ត ឬ ក្រុងទទួលជំនុំជំរះបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ។

ដើម្បីមានតំលៃត្រឹមត្រូវតាមច្បាប់តុលាការព្រហ្មទណ្ឌក៏ដូចជាតុលាការរដ្ឋប្បវេណី ទាមទារអោយមានចៅក្រមមួយរូប រដ្ឋអាជ្ញារងមួយរូប និងក្រឡាបញ្ជីមួយរូបជាអ្នកជំនួយការ ។

ចៅក្រមអាចជាប្រធាន អនុប្រធាន ឬចៅក្រមនៃតុលាការនោះតាមការចាត់តាំងរបស់ប្រធានតុលាការ ។

**មាត្រា ៩៧.-**

ញាតិសារលោហិត និងញាតិព័ន្ធរហូតដល់ថ្នាក់ទី៤គិតបញ្ចូលផង មិនអាចធ្វើជាសមាជិកនៃតុលាការតែមួយបានទេក្នុងឋានៈជាចៅក្រមក្តី ជាតំណាងអយ្យការក្តី ។

គោលការណ៏នេះមិនគ្រាន់តែអនុវត្តទៅលើតុលាការខេត្ត ឬក្រុងប៉ុណ្ណោះទេ ប៉ុន្តែទៅលើសាលាជំរះក្តីទាំងអស់ ទោះជាថ្នាក់ណាក៏ដោយ ។

**មាត្រា ៩៨.-**

ជាគោលការណ៏ មានវិសមិតភាពដាច់ខាតរវាងមុខងារចៅក្រម និងមុខងារតំណាងអយ្យការ ។

តំណាងអយ្យការដែលបានបំពេញមុខងាររបស់ខ្លួននៅពេលណាក៏ដោយនៃនីតិវិធី ពុំអាចធ្វើជាចៅក្រមនៅក្នុងរឿងក្តីដដែលនោះបានឡើយ ។

មានវិសមិតភាពផងដែររវាងមុខងារចៅក្រមស៊ើបអង្កេត និងមុខងារចៅក្រមជំនុំជំរះ ។

**មាត្រា ៩៩.-**

ក្នុងករណីដែលចៅក្រមស៊ើបអង្កេត ឬចៅក្រមជុំនុំជំរះមិននៅ ឬមានធុះ ចៅក្រមនោះត្រូវជំនួសដោយចៅក្រមម្នាក់ទៀតតាមការចាត់តាំងរបស់ប្រធានតុលាការសាមី ។

បើនៅតុលាការនោះគ្មានចៅក្រមទេ នោះរដ្ឋមន្ត្រីក្រសួងយុត្តិធមិ ត្រូវចាត់តាំងចៅក្រមម្នាក់របស់តុលាការនៃខេត្ត ឬក្រុងក្បែរគ្នានោះអោយជំនួស ។

**មាត្រា ១០០.-**

រដ្ឋអាជ្ញាអវត្តមាន ឬមានធុរៈ ត្រូវបានជំនួសជានិច្ចដោយរដ្ឋអាជ្ញារងម្នាក់ ក្នុងចំណោមរដ្ឋអាជ្ញាទាំង-ឡាយរបស់ខ្លួន ។ ក្នុងករណីគ្មានរដ្ឋអាជ្ញារងរដ្ឋមន្ត្រីក្រសួងយុត្តិធមិចាត់តាំងតំណាងម្នាក់នៃអយ្យការអមតុលាការខេត្តឬ ក្រុងក្បែរគ្នានោះអោយជំនួស ។

**មាត្រា ១០១.-**

បើមានកើតបទល្មើសមជ្ឈិមណាមួយក្នុងបរិវេណ និងក្នុងពេលសវនាការ ចៅក្រមត្រូវធ្វើកំណត់ហេតុមួយ អំពីរឿងនោះ ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ចំលើយរបស់ជនជាប់ចោទ និងរបស់សាក្សីហើយតុលាការអនុវត្តទោសតាមច្បាប់ហើយបន្តការជំនុំជំរះជាធម្មតា ដោយឥតចាកចេញពីទីកន្លែងសវនាការឡើយ ។

បើមានកើតបទឧក្រិដ្ឋណាមួយ នោះត្រូវចាប់ខ្លួនជនល្មើសភ្លាម ហើយនៅពេលជាមួយគ្នានោះ ត្រូវធ្វើកំណត់ហេតុមួយ ។ វត្ថុតាង និងជនជាប់ចោទនឹងត្រូវបានបញ្ជូនទៅចៅក្រមស៊ើបអង្កេតតាមលិខិតចោទប្រកាន់របស់អយ្យការ ។

**មាត្រា ១០២.-**

តុលាការព្រហ្មទណ្ឌ អាចទទួលបណ្តឹងដូចតទៅៈ

១-តាមដីកាចោទប្រកាន់ និងជូនរឿងផ្ទាល់របស់រដ្ឋអាជ្ញា

២-តាមដីកាបញ្ជូនរឿងរបស់ចៅក្រមស៊ើបអង្កេត

៣-តាមលិខិតបញ្ជូនរបស់សាលាឧទ្ធរណ៍ ឬតុលាការណាមួយទៀត

៤-តាមការនាំខ្លួនជនជាប់ចោទជាបន្ទាន់ទៅទីសវនាការ ក្នុងករណីបទល្មើសជាក់ស្តែង ។

**មាត្រា ១០៣.-**

តុលាការព្រហ្មទណ្ឌ អាចជំនុំជំរះបានតែទៅលើជនទាំងឡាយដែលគេបញ្ជូនទៅអោយខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ ។ បើជនដែលគេកោះហៅអោយចូលជាសាក្សី ត្រូវបានរកឃើញថា ជាចារី សហចារី

ឬអ្នកសមគំនិតនៃអំពើដែលតុលាការបានទទួលនោះ ជននោះនឹងអាចត្រូវបានតុលាការជំនុំជំរះលុះត្រាតែមានលិខិតចោទប្រកាន់ ឬដីកាបញ្ជូនរឿងអោយជំនុំជំរះ តាមទំរង់ និងរយៈពេលវេលាធម្មតាដូចមានកំណត់ក្នុងច្បាប់ ។

**មាត្រា ១០៤.**

តុលាការព្រហ្មទណ្ឌអាចជំនុំជំរះបានតែទៅលើអំពើដែលបានលើកឡើងក្នុងលិខិតចោទប្រកាន់ក្នុងដីកា ឬសាលក្រមបញ្ជូនរឿងដែលខ្លួនបានទទួល និងទៅលើកាលៈទេសៈទាំងឡាយដែលមានបច្ច័យជាប់ទាក់ទងពិតប្រាកដទៅនឹងអំពើល្មើស ហើយដែលកើតចេញពីការសួរដេញដោល ។

**មាត្រា ១០៥.**

បើតុលាការឃើញថា ការកំណត់បទល្មើសទៅលើអំពើ ដែលមាននៅក្នុងលិខិតបញ្ជូនមកខ្លួនពុំត្រឹមត្រូវទេនោះ តុលាការអាចកែតម្រូវបទល្មើសអោយត្រូវទៅនឹងអំពើល្មើសនោះបាន ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌជាក់លាក់ណាមួយ មិនត្រូវបន្ថែមអ្វីទៅលើធាតុផ្សំ ដែលទាក់ទងជិតស្និទ្ធទៅនឹងអំពើដែលបានលើកឡើងនៅក្នុងលិខិតចោទប្រកាន់ឬដីកាបញ្ជូនរឿងនោះឡើយ ។

**មាត្រា ១០៦.**

ក្នុងករណីកែប្រែបទល្មើស ពីបទមជ្ឈឹមទៅបទឧក្រិដ្ឋ តុលាការត្រូវបង្វិលសំណុំរឿងមករដ្ឋអាជ្ញាវិញ ដើម្បីធ្វើការសន្និដ្ឋានថ្មីក្នុងទម្រង់ និងរយៈកាលដែលមានចែងក្នុងច្បាប់ ។

**មាត្រា ១០៧.**

ប្រសិនបើអំពើដែលខ្លួនបានទទួលជំនុំជំរះនោះពុំទាន់ច្បាស់គ្រប់គ្រាន់ទេនោះ តុលាការអាចចាត់ការស៊ើបអង្កេតបន្ថែមដោយខ្លួនឯង ឬបង្វិលសំណុំរឿងមកអោយចៅក្រមស៊ើបអង្កេត ឬរដ្ឋអាជ្ញា ។

**មារត ១០៨.**

ជនជាប់ចោទត្រូវចូលខ្លួនមកចំពោះមុខតុលាការនៅគ្រប់ឱកាសជំនុំជំរះ ដែលត្រូវសួរបន្ថែមក្តី ឬសួរដេញដោលក្តី ។ បើជនជាប់ចោទបានចូលខ្លួននៅពេលសវនាការហើយជនជាប់ចោទត្រូវបានឆ្លើយការពារខ្លួនរួចហើយសាលក្រមដែលនឹងសំរេចនោះត្រូវជាសាលក្រមចំពោះមុខ ។

**មាត្រា ១០៩.**

អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬដើមបណ្តឹងរដ្ឋប្បវេណីអាចអោយមេធាវី ឬអ្នកការពារអោយចូលមកជំនួសខ្លួនបាន ។ ជនទាំងពីរប្រភេទខាងលើនេះ អាចចាត់ញាតិសាលោហិតខ្សែត្រង់ ឬអោយសហព័ន្ធរបស់ខ្លួនចូលមកជំនួសខ្លួនបាន ប៉ុន្តែត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ។

**មាត្រា ១១០.-**

ជនជាប់ចោទអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីអាចមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីបាន ។

មេធាវី ឬអ្នកការពារសិទ្ធិរបស់ភាគីនីមួយៗ អាចសុំចម្លង ឬសុំអោយស្មៀនរបស់ខ្លួន អោយមកចម្លងលិខិតទាំងឡាយនៃសំណុំរឿងនៅការិយាល័យក្រឡាបញ្ជី ដើម្បីរៀបចំការពារកូនក្ដីរបស់ខ្លួន ។

**មាត្រា ១១១.-**

បើជនជាប់ចោទ ដែលបានកោះហៅអោយចូលត្រឹមត្រូវហើយ ហើយមិនព្រមចូលមកទេ ការជំនុំជំរះត្រូវធ្វើដោយកំបាំងមុខ ។ ប្រសិនបើចៅក្រមឃើញថាជនជាប់ចោទមិនបានទទួលដីកាកោះ អោយចូលខ្លួនត្រឹមត្រូវតាមកាលកំណត់ទេ ចៅក្រមអាចលើករឿងទៅជំនុំជំរះនាពេលសវនាការខាងមុខទៀតបាន ។ ចៅក្រមនឹងអាចជំនុំជំរះដោយកំបាំងមុខបាន កាលបើជនជាប់ចោទមិនចូលខ្លួនតាមដីកាកោះថ្មីទេ ។

**មាត្រា ១១២.-**

កាលណាអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីមិនបានចូលខ្លួនមកទេ ការមិនចូលខ្លួនមកនេះ ត្រូវបានកត់សំគាល់ក្នុងបញ្ជីជំនុំជំរះ ។ តុលាការត្រូវកំណត់ថា តើទំនាក់ទំនងគតិយុត្តិ រវាងអ្នកទទួលខុសត្រូវ និងជនជាប់ចោទមាន ឬទេ ។ កាលបើមានពិរុទ្ធគ្រប់គ្រាន់លើជនល្មើស នោះតុលាការត្រូវវិភាគទៅលើលទ្ធផលនៃការខូចខាត ។

**មាត្រា ១១៣.-**

កាលណាដើមបណ្ដឹងរដ្ឋប្បវេណីមិនចូលខ្លួនមកទេ ហើយពិរុទ្ធភាពត្រូវបានទទួលស្គាល់ថាមានគ្រប់គ្រាន់ទៅលើជនជាប់ចោទ តុលាការកំណត់តាមការយល់ឃើញរបស់ខ្លួននូវតំលៃនៃការជួសជុលខូចខាតផ្នែករដ្ឋប្បវេណី កាលណាមានសេចក្ដីសុំច្បាស់លាស់នៅក្នុងពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

**មាត្រា ១១៤.-**

ថ្វីត្បិតតែជនជាប់ចោទមិនបានចូលខ្លួនតុលាការត្រូវតែចាត់ការដូចមានវត្តមានជនជាប់ចោទដែរគឺ ស្ដាប់ចម្លើយសាក្សីទាំងឡាយ ពិនិត្យគ្រប់ឯកសារ នឹងព័ត៌មានគ្រប់ប្រភេទដែលអាចអោយតុលាការឃើញការពិត ។ តុលាការអាចសំរេចអោយជនជាប់ចោទអវត្តមានរួចខ្លួនបាន កាលណាតុលាការឃើញថាពិរុទ្ធភាពមិនមានគ្រប់គ្រាន់ ។ ក្នុងករណីផ្ទុយទោសជនជាប់ចោទ តុលាការក៏អាចសំរេចអំពីស្ថានសំរាលទោសដល់ជនជាប់ចោទដែរ ។ និយាយសង្ខេបមក អវត្តមាននៃជនជាប់ចោទក្នុងពេលសវនាការមិនត្រូវចាត់ទុកជាស្ថានទំងន់ទោសទេ ។

**មាត្រា ១១៥.-**

ការផ្តន្ទាទោសសំរេចដោយកំបាំងមុខជនជាប់ចោទ ត្រូវចាត់ទុកជាអសារឥតការ កាលណាជនជាប់ចោទបានប្តឹងជំទាស់នឹងសាលក្រមនោះក្នុងរយៈពេល ១៥ថ្ងៃគិតពីថ្ងៃទទួលដំណឹងអំពីសាលក្រម ។

ប៉ុន្តែបើការឱ្យដំណឹងមិនបានធ្វើផ្ទាល់ដល់ជនជាប់ចោទទេ ឬបើគ្មានលិខិតអនុវត្តសាលក្រម ដែលជនជាប់ចោទបានដឹងនោះទេ បណ្តឹងជំទាស់អាចធ្វើបានរហូតដល់ពេលផុតរយៈវេលាអាជ្ញាយុកាលនៃទោស ។

**មាត្រា ១១៦.-**

បើជនជាប់ចោទឈប់នៅលំនៅដ្ឋានរបស់ខ្លួន ដែលបានចង្អុលប្រាប់ពីមុននោះ ហើយបើមន្ត្រីនគរបាលយុត្តិធម៌ទទួលបន្ទុកឱ្យដំណឹងមិនអាចរកឃើញលំនៅដ្ឋានថ្មីរបស់ជនជាប់ចោទទេ សេចក្តីជូនដំណឹងអំពីសាលក្រមកំបាំងមុខ ត្រូវយកទៅបិទនៅលំនៅដ្ឋានចុងក្រោយរបស់ជនជាប់ចោទនោះ។ សេចក្តីជូនដំណឹងនេះ ក៏ត្រូវយកទៅបិទផងដែរ នៅមន្ទីរគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ និងយកទៅផ្សាយតាមវិទ្យុជាតិ និងតាមសារព័ត៌មានជាផ្លូវការ ។

**មាត្រា ១១៧.-**

សេចក្តីជូនដំណឹងអំពីសាលក្រមកំបាំងមុខ កែប្រែសាលក្រមនេះទៅជាសេចក្តីសំរេចមួយរបស់តុលាការមានតំលៃគតិយុត្តិមានន័យថា សាលក្រមនេះមានប្រសិទ្ធភាពធ្វើឱ្យអាជ្ញាយុកាលនៃទោសមកជំនួសអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាវិញ ។ អាជ្ញាយុកាលនៃទោសមានរយៈពេល ៣ ឆ្នាំ សំរាប់បទល្មើសមជ្ឈឹម ១០ ឆ្នាំ សំរាប់បទល្មើសឧក្រិដ្ឋ។

គោលការណ៍នេះ ត្រូវបានអនុវត្តផងដែរ កាលណាសាលក្រមត្រូវបានអោយដឹង ដោយបិទនៅតាមលំនៅដ្ឋាន ឬបិទនៅតាមមន្ទីរគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ផ្សព្វផ្សាយតាមវិទ្យុជាតិ ឬតាមសារព័ត៌មានផ្លូវការ ។

សាលក្រមខាងលើនេះអាចអនុវត្តបានចំពោះសំណងរដ្ឋប្បវេណី កាលបើដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ ។

**មាត្រា ១១៨.-**

កាលណាមានការតវ៉ាអំពីសេចក្តីជូនដំណឹងនៃសាលក្រមកំបាំងមុខ ឧទាហរណ៍ដូចជា ក្នុងករណីលិខិតដើមនៃសេចក្តីជូនដំណឹងនេះត្រូវបានបាត់បង់ សេចក្តីជូនដំណឹងនោះចាត់ទុកដូចជាឥតបានធ្វើទេ ។

**មាត្រា ១១៩.-**

ការអោយដំណឹង ត្រូវអោយដោយផ្ទាល់ទៅសាមីខ្លួន នេះជាអាទិភាព បើរកសព្វគ្រប់ហើយមិនជួបសាមីខ្លួនទេនោះ ត្រូវចាត់វិធានការដូចមានចែងក្នុងមាត្រា ១១៦ ។

**មាត្រា ១២០.-**

តាមគោលការណ៍ បណ្តឹងជំទាស់ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ប៉ុន្តែ គេអាចធ្វើបណ្តឹងជំទាស់បានដែរ តាមសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតា ឬតាមបណ្តឹងធ្វើនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ណាមួយ ។ មន្ត្រីនេះត្រូវបញ្ជូនបណ្តឹងនោះជាប្រញាប់ទៅការិយាល័យក្រឡាបញ្ជីសាមី ។

**មាត្រា ១២១.-**

បណ្តឹងជំទាស់ផ្អាក់ការអនុវត្តសាលក្រម ហើយចាត់ទុកអង្គហេតុ និងតួក្តីទាំងអស់ក្នុងភាពដែលមាននៅពេលដែលសាលក្រមកំបាំងមុខបានសំរេច បន្ទាប់មកតុលាការដែលទទួលបណ្តឹងជំទាស់របស់ជនជាប់ចោទមានអំណាចរបស់ខ្លួនឡើងវិញពេញបរិបូរណ៍ក្នុងការជំនុំជំរះ ហើយអាចតម្លើងឬបន្ថយទណ្ឌកម្មទាំងឡាយរួមមានទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ និងទណ្ឌកម្មផ្នែករដ្ឋប្បវេណី ដែលសាលក្រមកំបាំងមុខបានកំណត់រួចហើយ ។

តុលាការក្រោយពីបានទទួលបណ្តឹងជំទាស់របស់ជនជាប់ចោទ អាចស្រង់ស្ថានទម្ងន់ទោសទាំងឡាយដែលខ្លួនពុំបានធ្វើនៅក្នុងសាលក្រមកំបាំងមុខ ឬសម្រេចអោយជនជាប់ចោទរួចខ្លួន ក្នុងករណីដែលមានចែងក្នុងច្បាប់ ។

**មាត្រា ១២២.-**

តុលាការពិនិត្យ តើបណ្តឹងជំទាស់ធ្វើឡើងត្រឹមត្រូវតាមច្បាប់ឬទេ ។ បើតុលាការឃើញថាបណ្តឹងនោះត្រឹមត្រូវ ហើយត្រូវប្រកាសថាទទួលបណ្តឹងទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ហើយចាត់ការជំនុំជំរះដល់អង្គសេចក្តី ដោយចាត់ទុកដូចជារឿងក្តីនេះទើបនឹងជូនមកចំពោះមុខខ្លួនជាលើកដំបូងនោះដែរ ។

**មាត្រា ១២៣.-**

បើអ្នកប្តឹងជំទាស់មិនបានចូលខ្លួនមកតាមការកំណត់របស់តុលាការទេ តុលាការចេញសាលក្រមកំបាំងមុខទុកជាចំពោះមុខ ។

**មាត្រា ១២៤.-**

សាលក្រមសម្រេចលើបណ្តឹងជំទាស់ គូភាគីអាចប្តឹងទៅសាលាឧទ្ធរណ៍បាន ។

**មាត្រា ១២៥.-**

ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ អាចធ្វើបានដោយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីញ៉ាំងចៅក្រមអោយជឿបាន ឧទាហរណ៍-ដូចជា ដោយការទទួលសារភាព ដោយចម្លើយសាក្សីឆ្លើយសមហេតុផល និងជាក់ច្បាស់ ដោយការពិនិត្យគ្រប់មុខសញ្ញា ដោយកោសល្យវិច្ច័យ ឬដោយមធ្យោបាយត្រឹមត្រូវតាមច្បាប់ដទៃទៀតដូចជាការទៅពិនិត្យដល់ទីកន្លែង..... ។ល។

តុលាការព្រហ្មទណ្ឌ ដើម្បីពង្រឹងជំនឿរបស់ខ្លួនអាចពិនិត្យទៅលើគ្រប់ឯកសារទាំងអស់ដែលបានដាក់មកអោយសួរដេញដោលនៅពេលសវនាការ និងដាក់អោយសួរតទល់រវាងគូភាគី និងរវាងមេធាវីដើម្បីចេញសាលក្រម ។ ចៅក្រមមិនត្រូវផ្អែកជំនឿរបស់ខ្លួនទៅលើការដឹងឮផ្ទាល់ខ្លួន ដែលខ្លួនបានទទួលក្រៅពីសវនាការតុលាការឡើយ ។

**មាត្រា ១២៦.-**

នៅតុលាការព្រហ្មទណ្ឌទាំងឡាយ ក្រឡាបញ្ជីត្រូវទទួលកត់ត្រានៅពេលសវនាការ សំដៅអោយសាលាឧទ្ធរណ៍អាចធ្វើការត្រួតពិនិត្យមានប្រសិទ្ធភាព អំពីនីត្យានុកូលភាពនៃនីតិវិធី និងអាចបានដឹងយ៉ាងគ្រប់គ្រាន់តាមត្រូវការ នូវការស៊ើបអង្កេតដោយផ្ទាល់មាត់ ដែលបានប្រព្រឹត្តទៅនាពេលសវនាការ ក្រឡាបញ្ជីត្រូវខិតខំស្រង់ដោយយកចិត្តទុកដាក់ខ្ពស់បំផុត នូវដំណើរការនៃនីតិវិធី ហើយកត់ត្រាចម្លើយសាក្សីទាំងឡាយ និងចម្លើយរបស់ជនល្មើស ។

សេចក្តីកត់ត្រាខាងលើនេះត្រូវបានចុះហត្ថលេខាដោយក្រឡាបញ្ជី និងបញ្ជាក់ដោយចៅក្រម ក្រោយពីបានពិនិត្យពិច័យរួចក្នុងរយៈពេលដប់ថ្ងៃក្រោយសវនាការដែលសាលក្រមនោះបានប្រកាស ហើយកិច្ចការនេះបើមិនធ្វើទេ ក្រឡាបញ្ជីត្រូវទទួលវិន័យរដ្ឋបាល ។

**មាត្រា ១២៧.-**

សេចក្តីកត់ត្រាដែលមានចុះហត្ថលេខាដោយក្រឡាបញ្ជី និងបញ្ជាក់ដោយចៅក្រម ត្រូវទុកជាបន្ទាល់នូវខ្លឹមសាររបស់វារហូតដល់មានភស្តុតាងផ្ទុយ ។ ក្នុងករណីមានសេចក្តីមិនស្របគ្នារវាងសេចក្តីកត់ត្រា និងសាលក្រមដើម គេត្រូវយកសេចក្តីក្នុងសាលក្រមដើមទុកជាបានការ ។

**មាត្រា ១២៨.-**

ការស៊ើបអង្កេតនៅពេលសវនាការត្រូវធ្វើជាសារធារណៈ បើពុំដូច្នោះទេនឹងត្រូវទុកជាមោឃៈ ។ ការផ្សព្វផ្សាយជាសាធារណៈនេះ មិនមែនសំរាប់តែសវនាការដែលប្រកាសសាលក្រមទេ ប៉ុន្តែសំរាប់សវនាការដែលធ្វើការស៊ើបអង្កេត និងការសួរដេញដោល ។ ដូចនេះសាលក្រមត្រូវតែមានបញ្ជាក់អំពីការផ្សាយជាសាធារណៈនេះ ពីព្រោះបើគ្មានសេចក្តីបញ្ជាក់នេះទេ សាលក្រមនោះត្រូវទុកជាមោឃៈ ។

**មាត្រា ១២៩.-**

ប៉ុន្តែការជំនុំជំរះអាចធ្វើជាសម្ងាត់ កាលបើការធ្វើជាសាធារណៈអាចនាំឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់ប្រពៃណីល្អ ។ សវនាការជាសម្ងាត់ធ្វើតែទៅលើភាគមួយនៃការសួរដេញដោលប៉ុណ្ណោះ ។ មានន័យម៉្យាងទៀតថា ចិរវេលានៃការធ្វើជាសម្ងាត់ អាចត្រឹមតែក្នុងពេលស៊ើបអង្កេតប៉ុណ្ណោះ

រីឯការប្រកាសសាលក្រម ត្រូវធ្វើជាសាធារណៈ បើពុំនោះទេត្រូវទុកជាមោឃៈ ។

**មាត្រា ១៣០.-**

ចៅក្រមជាអ្នករក្សាសេចក្តីស្ងប់ស្ងៀមនៃសវនាការ និងជាអ្នកដឹកនាំសួរដេញដោល ។ ក្នុងការសួរដេញដោល ចៅក្រមអាចបញ្ឈប់ ឬយកចេញអ្វីៗ ដែលនាំអោយការសួរដេញដោលនោះវែងអន្លាយឥតប្រយោជន៍ គឺឥតបានផ្តល់ការបំភ្លឺរកការពិត ។

កាលណាមានការតវ៉ា រវាងតំណាងអយ្យការ ឬដើមបណ្តឹងរដ្ឋប្បវេណីជាមួយជនជាប់ចោទ ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីអំពីអត្ថប្រយោជន៍នៃវិធានការណាមួយក្នុងការស៊ើបអង្កេត ការស្តាប់ចម្លើយ សាក្សីការតាំងសំនួរផ្សេងៗ ឬបញ្ហាដទៃទៀតនោះ ចៅក្រមអាចសរេចដោយចេញបញ្ជា ដែលគ្រាន់តែចុះនិទ្ទេសក្នុងសេចក្តីកត់ត្រាសវនាការ លើចំណុចដែលថា តើវិធានការនោះត្រូវបានអនុញ្ញាត ឬត្រូវបានបដិសេធចោល ។

**មាត្រា ១៣១.-**

ភាគីរងគ្រោះ អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានជានិច្ច ក្នុងពេលដែលចៅក្រមពុំទាន់ចេញសាលក្រម ។ ភាគីរងគ្រោះមិនចាំបាច់ដាក់ពាក្យដែលមានរ៉ាយរ៉ាប់អំពីមធ្យោបាយអន្តរាគមន៏របស់ខ្លួននោះទេ គឺគ្រាន់តែជំរាបនៅពេលសវនាការថា : ខ្លួនសូមតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសុំអោយចុះនិទ្ទេសអពីសំណូមពរនេះ ហើយចាប់ធ្វើការសន្និដ្ឋាន ។

**មាត្រា ១៣២.-**

នៅពេលបើកសវនាការ ចៅក្រមប្រកាសលើកសំណុំរឿងមកជំនុំជំរះ ។. ក្រឡាបញ្ជី ហៅឈ្មោះភាគីនិងសាក្សីទាំងឡាយនៃរឿងព្រមទាំងត្រួតពិនិត្យលើអត្តសញ្ញាណនៃជនទាំងនោះ ។ ភាគីនីមួយៗ អង្គុយនៅកន្លែងដែលទុកអោយខ្លួននៅក្នុងបន្ទប់ជំនុំជំរះ ។ សាក្សីទាំងឡាយត្រូវថយខ្លួនទៅនៅក្នុងបន្ទប់មួយដែលគេរៀបចំទុកដោយឡែក ហើយដែលសាក្សីពុំអាចឃើញ ឬស្តាប់ឮអ្វីៗដែលធ្វើនៅបន្ទប់ជំនុំជំរះ ។ សាក្សីទាំងនោះពុំអាចទាក់ទងគ្នាបានឡើយ ។

បន្ទាប់មកទៀត ចៅក្រមស្តាប់ការរ៉ាយរ៉ាប់របស់ជនជាប់ចោទ អំពីដំណើររឿងដែលចោទប្រកាន់មកលើខ្លួន ។ ក្រោយពីបានស្តាប់សេចក្តីរ៉ាយរ៉ាប់ផ្ទាល់មាត់របស់ជនជាប់ចោទរួចហើយ ចៅក្រមចាប់ផ្តើមសួរជនជាប់ចោទនូវបញ្ហាមានប្រយោជន៏ដល់រឿង ។ ការសួរនោះត្រូវបានបំពេញដោយសំនួររបស់ភាគីឯទៀត តាមរយៈចៅក្រម ។

ប្រសិនបើគ្មានការជំទាស់ពីភាគីណាមួយ រាប់ទាំងតំណាងអយ្យការផង ចៅក្រមតាំងសំនួរដែលគេសួរតាមរយៈខ្លួន ។ បើមានការជំទាស់ ចៅក្រមត្រូវសំរេចដោយគិតថា តើសំនួរនោះត្រូវចោទសួរឬទេ ។

សំនួរទាំងឡាយត្រូវចោទសួរតាមរយៈចៅក្រម លើកលែងតែសំនួររបស់តំណាងអយ្យការមេធាវី ឬអ្នកការពារ ដែលអាចចោទសួរផ្ទាល់តែម្តង ក្រោយពីបានទទួលការអនុញ្ញាតពីចៅក្រម ។

បន្ទាប់ពីជនជាប់ចោទ ចៅក្រមស្តាប់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឆ្លើយតាមមធ្យោបាយការពារខ្លួនរបស់អ្នកនោះ ។ មធ្យោបាយការពារខ្លួនត្រូវសំដៅទៅលើហេតុការណ៍ដែលអ្នកនោះបានដឹង ហើយជាអាទិ៍ទៅលើទំនាក់ទំនងដែលជាហេតុនាំអោយអ្នកនោះទទួលខុសត្រូវខាងរដ្ឋប្បវេណី ។

បន្ទាប់មកទៀត ចៅក្រមស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីប្រសិនបើមាន ដែលបានតាំងខ្លួនត្រឹមត្រូវតាមច្បាប់ ។ ចៅក្រមស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អំពីការដែលជននោះបានដឹង ជាអាទិ៍អំពីកត្តានៃភស្តុតាងបញ្ជាក់ពីការខូចខាតដែលខ្លួនត្រូវរងគ្រោះរួមមានតំលៃ និងទំនាក់ទំនងហេតុនិងផល រវាងខ្លួន និងបទល្មើស ។

**មាត្រា ១៣៣.-**

បន្ទាប់មកចៅក្រមស្តាប់ចម្លើយរបស់សាក្សីតាមលំដាប់លំដោយគឺ : សាក្សីបន្ទុក សាក្សីខាងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដោះបន្ទុក ។ លំដាប់លំដោយនេះនឹងអាចផ្លាស់ប្តូរ លុះណាតែមានហេតុផលសំខាន់ដែលត្រូវធ្វើដូចនោះ ។

ចៅក្រមអាចមិនចាំបាច់ស្តាប់ចម្លើយណាមួយបាន កាលណាខ្លួនយល់ឃើញថា ចម្លើយនោះពុំមានប្រយោជន៍ដល់ការបញ្ជាក់នូវការពិត ។ ក្នុងករណីមានការជំទាស់ចៅក្រមត្រូវសំរេចរឿងនេះដោយដីកាបង្គាប ដែលត្រូវចុះក្នុងកំណត់ហេតុសវនាការ ។

**មាត្រា ១៣៤.-**

សាក្សីទាំងឡាយណាដែលមិនបានស្បថ នៅពេលស៊ើបអង្កេតត្រូវស្បថសិនមុននឹងឆ្លើយ ។

សាក្សីទាំងឡាយណាដែលចូលមកឆ្លើយតបតាមអំណាចឆន្ទានុសិទ្ធិ នៃចៅក្រមនោះមិនចាំបាច់ស្បថឡើយ ។

សាក្សីក្រោយពីបានឆ្លើយជូនតុលាការរួចហើយ អាចនៅក្នុងបន្ទប់សវនាការបាន ។ តាមសំណូមពររបស់សាក្សី ចៅក្រមអាចអនុញ្ញាតអោយចេញទៅក្រៅបាន កាលណាសាក្សីនោះមិនចាំបាច់ឆ្លើយបញ្ជាក់អ្វីទៀតនោះ ។

**មាត្រា ១៣៥.-**

វត្ថុតាងទាំងឡាយត្រូវយកមកបង្ហាញម្តងទៀតដល់សាក្សី និងគូភាគី ប៉ុន្តែទម្រង់បែបបទនេះកាលណាមិនបានបំពេញក៏មិនបណ្តាលអោយការជំនុំជំរះមានមោឃភាពដែរ ។

**មាត្រា ១៣៦.-**

បើជនជាប់ចោទឬសាក្សីជាមនុស្ស គ ថ្លង់ ប៉ុន្តែចេះសរសេរអក្សរនោះ ក្រឡាបញ្ជីត្រូវសរសេរសំនួរ និងការកត់សំគាល់ផ្សេងៗអោយទៅជនជប់ចោទឬសាក្សី គ ថ្លង់នោះ ដើម្បីអោយឆ្លើយមកវិញដោយលាយលក្ខណ៍អក្សរ ។ បើជន គ ថ្លង់ មិនចេះសរសេរអក្សចៅក្រមត្រូវតែងតាំងដោយឯកឯងនូវជនម្នាក់ដែលមានទម្លាប់ទាក់ទងមនុស្ស គ ថ្លង់ ដោយកាយវិការដើម្បីធ្វើជាអ្នកបកប្រែ ។

**មាត្រា ១៣៧.-**

ក្រោយពីការសួរដេញដោល ចៅក្រមត្រូវបើកអោយនិយាយជាបន្តបន្ទាប់គ្នា គឺដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ជនជាប់ចោទ មេធាវី ឬអ្នកការពារដើមបណ្តឹង រដ្ឋប្បវេណី តំណាងអយ្យការ មេធាវី ឬអ្នកការពារអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ហើយជាចុងក្រោយបង្អស់ មេធាវី ឬអ្នកការពារជនជាប់ចោទ ។ ការបំពេញទំរង់បែបបទខាងលើនេះ ត្រូវកត់ត្រាក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម បើពុំធ្វើដូច្នោះទេត្រូវទុកជាមោឃៈ ។

**មាត្រា ១៣៨.-**

តំណាងអយ្យការ ត្រូវមានមតិត្រឹមត្រូវតែទៅលើអង្គហេតុនៃការសួរដេញដោលប៉ុណ្ណោះទេ ប៉ុន្តែនៅលើឧប្បត្តិហេតុទាំងឡាយដែរ ហើយកាលណាតំណាងអយ្យការប្រកាសថា យល់ព្រមតាមសេចក្តីសំរេចរបស់តុលាការ នោះទើបចាត់ទុកថាគ្រប់គ្រាន់តាមផ្លូវច្បាប់ ។

**មាត្រ ១៣៩.-**

ដរាបណាចៅក្រមពុំទាន់ប្រកាសសាលក្រមរបស់ខ្លួននៅឡើយទេ ដរាបនោះគូភាគីអាចត្រូវបានអនុញ្ញាតអោយធ្វើសេចក្តីសន្និដ្ឋាន ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ទៅតុលាការជានិច្ច ។

**មាត្រា ១៤០.-**

តុលាការជំនុំជំរះដោយចេញសាលក្រមរបៀបទៅអញ្ញត្រកម្មទាំងអស់ដែលតំណាងអយ្យការ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងជនជាប់ចោទយល់ថា ត្រូវលើកយកមកជជែកគ្នាពីព្រោះមានប្រយោជន៍ ។

ប្រសិនបើអញ្ញត្រកម្មស្តីពីអសមត្ថកិច្ច នោះតុលាការត្រូវតែសំរេចជាមុនសិននៅលើអញ្ញត្រកម្មស្តីពីអសមត្ថកិច្ចនោះ ។

ប៉ុន្តែបើសិនណា ដើម្បីនឹងវាយតំលៃទៅលើអញ្ញត្រកម្មស្តីពីអសមត្ថកិច្ចនោះបាន លុះត្រាតែពិនិត្យដល់អង្គសេចក្តីសិន នោះតុលាការអាចសំរេចភ្ជាប់ឧប្បត្តិហេតុនោះទៅអង្គសេចក្តីបាន ។ បន្ទាប់មកតុលាការត្រូវ

សំរេចអំពីសមត្ថកិច្ចដោយចេញសេចក្តីសំរេចមួយផ្សេងពីសេចក្តីសំរេចលើអង្គសេចក្តី ។ បើតុលាការសំរេចថាគ្មានសមត្ថកិច្ចនោះតុលាការមិនបាច់ពិនិត្យដល់អង្គសេចក្តីឡើយ ។

**មាត្រា ១៤១.-**

កាលណាការសួរដេញដោលការសន្និដ្ឋានទោស ការសន្និដ្ឋានការពារបានធ្វើចប់សព្វគ្រប់ ហើយចៅក្រមប្រកាសថយខ្លួនទៅបន្ទប់សម្ងាត់សំរាប់ពិភាក្សា ។ ចាប់ពីពេលនេះទៅ ការជូនសំអាងឬពាក្យសុំណាមួយមិនអាចធ្វើបានទៀតឡើយ ។

**មាត្រា ១៤២.-**

សាលក្រមទាំងអស់ត្រូវប្រកាសជាសាធារណៈ មានន័យថា ត្រូវអានយ៉ាងឮដោយចៅក្រម ។ សាលក្រមត្រូវបានសំរេចចេញក្នុងថិរវេលាយ៉ាងខ្លីបំផុត ។ កាលណាសាលក្រមពុំអាចចេញភ្លាមបានទេ ចៅក្រមត្រូវប្រកាសនៅពេលសវនាការ និងអំពីថ្ងៃសវនាការខាងមុខ ដែលសាលក្រមនោះនឹងត្រូវប្រកាសដើម្បីឱ្យអ្នកមានប្រយោជន៍ក្នុងរឿងក្តីនោះចូលមកស្តាប់ ។

**មាត្រា ១៤៣.-**

សាលក្រមទាំងឡាយត្រូវមានពីរផ្នែក គឺ : ផ្នែកខាងលក្ខណសម្បត្តិ និង ផ្នែកសាលក្រមសុទ្ធសាធ ។

១-ផ្នែកខាងលក្ខណៈសម្បត្តិ ដែលសសេរនៅក្បាលសាលក្រមត្រូវមានៈ គោត្តនាម និងនាម វិជ្ជាជីវៈ ទីលំនៅ និងតួនាទីនៃគូភាគី គោត្តនាម និងនាមរបស់មេធាវី ឬអ្នកការពារបទចោទប្រកាន់ និងសំណូមពររបស់គូក្តីប្រសិនបើមានសុំសេចក្តីរំលឹកអំពីនីតិវិធី ដែលបានប្រព្រឹត្តដោយមានចុះនិទ្ទេសនូវអំពើ និងកិច្ចធំៗ ព្រមទាំងឧប្បត្តិហេតុនានា ដែលតុលាការបានសំរេចហើយ ។ លក្ខណៈសម្បត្តិនេះក៏ត្រូវមានផងដែរនូវសំនួរ និងចំលើយ ដែលបានធ្វើនៅពេលសវនាការ ។

២-ផ្នែកខាងសាលក្រមសុទ្ធសាធ ត្រូវចែកចេញជាពីរផ្នែកទៅទៀត គឺៈ ផ្នែកខាងសំអាងហេតុ និងផ្នែកខាងសេចក្តីសំរេច ។

ក-សំអាងហេតុ គឺយោបល់ទាំងឡាយ ដែលនាំឱ្យកំនត់ចេញសេចក្តីសំរេចរបស់តុលាការ ។

ខ-សេចក្តីសំរេចបញ្ជាក់ពីវិធានការទាំងឡាយដែលបានចាត់ ឬការផ្តន្ទាទោសដែលតុលាការបានសំរេច ។

**មាត្រា ១៤៤.-**

សាលក្រមណាក៏ដោយ ត្រូវមានសំអាងហេតុគ្រប់ចំណុចសំខាន់ៗ នៃបទចោទប្រកាន់ និងគ្រប់ចំណុចនៃពាក្យសុំរបស់គូភាគី ។ សំអាងហេតុត្រូវតែច្បាស់លាស់ មានន័យថា បញ្ជាក់ឱ្យប្រាកដនូវគំនិតរបស់ចៅក្រមដោយឥតនាំអោយមានការភ័ន្តច្រឡំ ឬសេចក្តីផ្ទុយគ្នានោះឡើយ ។

សេចក្តីសំរេចដែលជាផ្នែកសំខាន់បំផុតនៃសាលក្រម ក៏ត្រូវតែសរសេរឱ្យបានច្បាស់លាស់ ដូចសំអាងហេតុដែរ ។ នៅក្នុងសេចក្តីសំរេច ត្រូវចុះអត្ថបទច្បាប់ទាំងឡាយ ដែលការសំរេចត្រូវផ្អែកទៅលើ ។

**មាត្រា ១៤៥.-**

សាលក្រមត្រូវតែសរសេរភ្លាម១ ហើយត្រូវអាននៅពេលសវនាការ កាលណាចៅក្រមត្រលប់មកពីបន្ទប់សម្ងាត់សំរាប់ពិភាក្សាវិញ ។

មានតែផ្នែកខាងសំអាងហេតុ និងផ្នែកខាងសេចក្តីសំរេចទេ ដែលត្រូវអានជាសាធារណៈ ។ មុននឹងអានសាលក្រម ចៅក្រមត្រូវចុះហត្ថលេខានៅក្នុងសាលក្រមនោះសិន ។

**មាត្រា ១៤៦.-**

ជនជាប់ចោទដែលត្រូវបានរួចខ្លួន អាចស្នើភ្លាមបាននូវពាក្យសុំសំណងជំងឺចិត្ត ។ ប៉ុន្តែ ពាក្យបណ្តឹងសុំនោះ នឹងអាចទទួលបាន កាលបើជននោះបញ្ជាក់បានថា ដើមចោទមានកំហុស ហើយកំហុសនោះបាននាំអោយមានបណ្តឹងឡើង ដោយអសុទ្ធចិត្ត ឬដោយឥតបានពិចារណាឱ្យបានល្អិតល្អន់ ។ មានតែតុលាការដែលកាត់សេចក្តីរឿងនោះទេ ដែលមានសមត្ថកិច្ចជំនុំជំរះរឿងបណ្តឹងនេះ ។

**មាត្រា ១៤៧.-**

ចំពោះការបង្វិលវត្ថុតាងឱ្យទៅជនជាប់ចោទវិញ ក្នុងករណីដែលជនជាប់ចោទរួចខ្លួន តុលាការត្រូវបង្គាប់ឱ្យប្រគល់វត្ថុតាងនោះឱ្យទៅជនជាប់ចោទ កាលណាឃើញថាវត្ថុទាំងនោះ ជារបស់ជនជាប់ចោទពិតប្រាកដ ។ បើមានសេចក្តីសង្ស័យ សូម្បីតែបន្តិចបន្តួចក៏ដោយតុលាការត្រូវ ប្រកាសថា វត្ថុតាងត្រូវបង្វិលទៅឱ្យម្ចាស់ដើមត្រឹមត្រូវតាមច្បាប់វិញ ។ នេះគឺបើឱ្យគូក្តីដែលមានប្រយោជន៍ និងសុំសងវត្ថុនោះទៅតុលាការផ្នែករដ្ឋប្បវេណីដើម្បីកំណត់រកម្ចាស់ដើមត្រឹមត្រូវតាមច្បាប់ឱ្យឃើញ ។

**មាត្រា ១៤៨.-**

ទោះជាក្នុងករណីជនជាប់ចោទត្រូវបានរួចខ្លួនក៏ដោយ វត្ថុតាងត្រូវតែប្រកាសរឹបអូស កាលណាច្បាប់ចែងឱ្យរឹបអូស ឧទាហរណ៍ -ដូចជាក្នុងករណីកាន់កាប់គ្រឿងអាវុធដោយខុសច្បាប់ ករណីក្លែងវត្ថុផ្សេង១ ។ល ។

**មាត្រា ១៤៩.-**

បើអំពើប្រព្រឹត្តនោះគ្រាន់តែជាបទលហុប៉ុណ្ណោះ តុលាការត្រូវកំណត់ទណ្ឌកម្មជាលហុ ហើយសំរេចសំណងជំងឺចិត្ត ប្រសិនបើមានពាក្យសុំ ។

**មាត្រា ១៥០.-**

នៅក្នុងសាលក្រមត្រង់សេចក្តីសំរេច ហើយបន្ទាប់ពីបានប្រកាសពិរុទ្ធភាព នៃជនជាប់ចោទ និងការ

ទទួលខុសត្រូវរបស់អ្នកទទួល ផ្នែករដ្ឋប្បវេណី សាលក្រមត្រូវកំណត់មូលទោស និងអនុទោស ប្រសិនបើមាន។ ម្យ៉ាងវិញ ទៀតសាលក្រមត្រូវមានចុះជានិទ្ទេស នូវអត្ថបទច្បាប់ដែល លើកយកមកអនុវត្ត។

**មាត្រា ១៥១.-**

ជាមួយគ្នានឹងការសំរេចអំពីទោស តុលាការក៏ត្រូវសំរេចផងដែរអំពីការជួសជុលសំណង និងជំងឺចិត្ត។

**មាត្រា ១៥២.-**

ជនជាប់ចោទ ដែលតុលាការសំរេចអោយរួចខ្លួន ត្រូវដោះលែងភ្លាម ប្រសិនបើសាលក្រមមិនត្រូវបានគេប្តឹងឧទ្ធរណ៍ភ្លាមទេ។ ប្រសិនបើតុលាការសំរេចផ្តន្ទាទោស ហើយបើជនជាប់កំពុងនៅជាប់ប្តឹងឧទ្ធរណ៍ ជនជាប់ចោទនោះនៅជាប់ឃុំខ្លួនជាបណ្តោះអាសន្នដដែល។

**មាត្រា ១៥៣.-**

ក្នុងករណីផ្តន្ទាទោស សាលក្រមត្រូវបានអនុវត្ត និងធានាដោយរដ្ឋអាជ្ញាចំពោះទោសគុក និងការទារប្រាក់ពិន័យ។ ចំណែកឯការជួសជុលសំណង និងជម្ងឺចិត្តនោះ ត្រូវបានអនុវត្តក្រោយពីមានពាក្យសុំនៃដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗបានសុំតាមចំណែករបស់ខ្លួន។

**មាត្រា ១៥៤.-**

បើជនជាប់ចោទនៅក្រៅឃុំការប្តឹងឧទ្ធរណ៍ផ្អាកការអនុវត្តន៏សាលក្រមសិនមានន័យថា ជនជាប់ចោទត្រូវនៅក្រៅឃុំដដែល ។

**មាត្រា ១៥៥.-**

គ្រប់សាលក្រមចំពោះមុខ របស់តុលាការព្រហ្មទណ្ឌ អាចត្រូវប្តឹងឧទ្ធរណ៍បានក្នុងរយៈពេលពីរខែគត់គិតពីថ្ងៃប្រកាសសាលក្រម ។

## ជំពូកទី៦

## សាលាឧទ្ធរណ៍

**មាត្រា ១៥៦.-**

សាលាឧទ្ធរណ៍តាំងនៅភ្នំពេញ ។

សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍លាតសន្ធឹងនៅលើដែនដីទាំងមូលនៃរដ្ឋកម្ពុជា ។

**មាត្រា ១៥៧.-**

ក្នុងរឿងព្រហ្មទណ្ឌក៏ដូចជារឿងក្តីឯទៀតដែរ សាលាឧទ្ធរណ៍ជំនុំជំរះបណ្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចទាំងឡាយរបស់តុលាការយោធា តុលាការខេត្ត-ក្រុងព្រមទាំងសេចក្តីសំរេចទាំងឡាយរបស់

អយ្យការអមតុលាការថ្នាក់ក្រោមទាំងនោះ ។

**មាត្រា ១៥៨.-**

សាលាឧទ្ធរណ៍ក្នុងពេលជំនុំជំរះត្រូវមានសមាសភាព ចៅក្រម ៣រូប ដែលមួយរូបជាប្រធាន តំណាងមហាអយ្យការមួយរូប និងក្រឡាបញ្ជីមួយរូប ។

**មាត្រា ១៥៩.-**

អមសាលាឧទ្ធរណ៍មានមហាអយ្យការមួយដែលមានអគ្គរដ្ឋអាជ្ញា និង អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញា ។ សមត្ថកិច្ចរបស់អគ្គរដ្ឋអាជ្ញាលាតសន្ធឹងលើដែនដីទាំងមូលនៃរដ្ឋកម្ពុជា ។ ក្នុងករណីមានធុរៈដោយមានជំងឺ ឬដោយហេតុអ្វីផ្សេងទៀត អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានជំនួសដោយអគ្គរដ្ឋអាជ្ញារង ដែលចាស់ជាងគេ ក្នុងបណ្តាសក្តិខ្ពស់ជាងគេ ប្រសិនបើមានអគ្គរដ្ឋអាជ្ញារងច្រើនរូប ។

**មាត្រា ១៦០.-**

មុខងារសំខាន់របស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ គឺធ្វើសេចក្តីសន្និដ្ឋាន នៅពេលសវនាការ និងប្តឹងសាទុក្ខទៅតុលាការកំពូល ចំពោះសាលដីការសាលាឧទ្ធរណ៍ដែលខ្លួនឃើញថា មានការភ័ន្តច្រឡំ ឬខុសច្បាប់ ។

**មាត្រា ១៦១.-**

ជនមានសិទ្ធិប្តឹងឧទ្ធរណ៍គឺៈ

-ជនជាប់ចោទ ឬអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី

-ដើមបណ្តឹងរដ្ឋប្បវេណី

-រដ្ឋអាជ្ញា ។

**មាត្រា ១៦២.-**

ជនជាប់ចោទ ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលចង់ ប្រើសិទ្ធិឧទ្ធរណ៍របស់ខ្លួន ត្រូវប្រើសិទ្ធិនោះ ដោយខ្លួនឯង ឬដោយអាជ្ញានុការី "អ្នកទទួលអំណាច"អំណាចដែលប្រគល់ទៅអោយអាជ្ញានុការីនោះ ត្រូវធ្វើជាពិសេស ។ មានតែឪពុក ឬម្តាយនៃអនីតិជនទេ ទើបអាចប្តឹងឧទ្ធរណ៍ជំនួសកូនដោយមិនបាច់មានលិខិតប្រគល់អំណាចពិសេសនោះ ។ រីឯអ្នកអាណាព្យាបាលក៏ដូច្នោះដែរ ។

**មាត្រា ១៦៣ៈ**

បណ្តឹងឧទ្ធរណ៍មានអានុភាពផ្ទេរសមត្ថកិច្ច មានន័យថា បណ្តឹងឧទ្ធរណ៍ប្រគល់ដល់សាលាជំរះក្តីជាន់ទី២ "សាលាឧទ្ធរណ៍" គ្រប់ចំណុចទាំងអស់នៃអង្គហេតុ និង អង្គច្បាប់ ដែលតុលាការជាន់ក្រោមបានពិនិត្យ ។

**មាត្រា ១៦៤.-**

សាលាឧទ្ធរណ៍នៅពេលទទួលជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ប្តឹងដោយជនជាប់ចោទ ពុំអាចដាក់បន្ថែមទម្ងន់ទោសលើជនជាប់ចោទបានឡើយ ។ សាលាឧទ្ធរណ៍អាចកែប្រែសាលក្រមបាន តែក្នុងន័យអោយផលប្រយោជន៍ទោជនជាប់ចោទ ។

សាលាឧទ្ធរណ៍អាចកែប្រែបទល្មើស ដែលចៅក្រមជាន់ទី១បានសំរេច ប៉ុន្តែល័ក្ខខ័ណ្ឌដែលពុំមានការបន្ថែមទម្ងន់អ្វីទៅលើការផ្តន្ទាទោសជនជាប់ចោទទេ ។

សាលាឧទ្ធរណ៍អាចអនុវត្តផងដែរលើអង្គហេតុ នូវច្បាប់ព្រហ្មទណ្ឌផ្សេងពីអត្ថបទច្បាប់ព្រហ្មទណ្ឌដែលសាលក្រមមុនបានសំអាងដោយរក្សាការផ្តន្ទាទោសនៅដដែល ។

**មាត្រា ១៦៥.-**

សាលាឧទ្ធរណ៍មិនអាចសំរេចលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ បន្ថែមអនុទោសទៅលើមូលទោសដែលចៅក្រមជាន់ទី ១ ភ្លេចសំរេចនោះបានទេ ។

ប៉ុន្តែក្នុងករណី ដែលអនុទោសត្រូវតែមានជាច់ខាតនោះ សាលាឧទ្ធរណ៍ត្រូវតែពន្យល់អំពីការដែលខ្លួនមិនអាចកែតម្រូវការភ្លេចរបស់ចៅក្រមជាន់ទី ១ បានដោយគ្មានបណ្តឹងពីអយ្យការ ។

ប្រសិនបើសាលាឧទ្ធរណ៍តម្កល់សាលក្រម ដោយឥតបញ្ជាក់ដូចខាងលើនេះទេ សាលដីការបស់សាលាឧទ្ធរណ៍ត្រូវមានកំហុសដូចសេចក្តីសម្រេចរបស់តុលាការជាន់ក្រោមដែរ ។ ហេតុដូចនេះ សាលដីកានោះត្រូវទុកជាមោឃៈ ។

**មាត្រា ១៦៦.-**

សាលាឧទ្ធរណ៍មិនអាចសំរេចលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទដោយតម្លើងចំនួនទឹកប្រាក់នៃសំណងនិងជំងឺចិត្តដែលតុលាការជាន់ទី ១ សំរេចអោយសងទៅដើមបណ្តឹងរដ្ឋប្បវេណីនោះបានឡើយ ។

**មាត្រា ១៦៧.-**

សាលាឧទ្ធរណ៍អាចកំណត់តម្លើងអត្រាប្រាក់ពិន័យបាន ដោយលុបទោសគុក ។ តុលាការសំរេចកែប្រែទោសគុកជាទោសពិន័យវិញទោះជាទោសគុកនោះមានថិរវេលាតិចយ៉ាងណាក៏ដោយ ហើយអត្រាពិន័យខ្ពស់យ៉ាងណាក៏ដោយ ដោយហេតុថា ទម្ងន់ទោសមិនស្ថិតនៅលើថិរវេលា ឬអត្រាទេ ប៉ុន្តែនៅលើចំណាត់ថ្នាក់នៃស្ថានទម្ងន់ទោស មានន័យថា ទោសគុកធ្ងន់ជាងទោសពិន័យ ។

**មាត្រា ១៦៨.-**

ផ្ទុយទៅវិញ សាលាឧទ្ធរណ៍អាចសំរេចទៅលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ នូវការដាក់គុកបង្ខំលើរូបកាយដែលតុលាការថ្នាក់ក្រោមភ្លេចកំណត់ ពីព្រោះនេះពុំមែនជាទោសទេគឺជានីតិវិធីអនុវត្តសាលក្រមដែល

ត្រូវតែមានតាមច្បាប់កំណត់ ។

**មាត្រា ១៦៩.-**

ក្នុងករណីដែលតុលាការជាន់ទីមួយសំរេចអោយជនជាប់ចោទរួចខ្លួន ហើយដែលដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ទូទៅនោះ សាលាឧទ្ធរណ៍អាចសំរេចអំពីទោសទាំងឡាយបាន រួមទាំងអនុទោស និង សំណងជម្ងឺចិត្តផង ។

**មាត្រា ១៧០.-**

បណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និង បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ទោះជាគ្មានបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទក៏ដោយលើករឿងទាំងអស់ដែលតុលាការថ្នាក់ក្រោមបានសំរេចរួច ហើយទាំងបញ្ហាដាក់បន្ទុក និងបញ្ហាដោះបន្ទុក អោយសាលាឧទ្ធរណ៍ពិនិត្យ និង សំរេច ។ ដូចនេះ សាលាឧទ្ធរណ៍អាចកំណត់តម្លើងទណ្ឌកម្មបាន ឬសំរេចអោយជនជាប់ចោទរួចខ្លួន ។

**មាត្រា ១៧១.-**

សាលាឧទ្ធរណ៍អាចសំរេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា អំពីអនុទោសទាំងឡាយដែលចៅក្រមជាន់ទីមួយភ្លេចកំណត់ ។

**មាត្រា ១៧២.-**

ប៉ុន្តែបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញានឹងមានអានុភាពយ៉ាងនេះបានលុះណាតែបណ្តឹងនោះជាបណ្តឹងទូទៅ ។

បើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ក៏រិតទៅលើតែអ្វីមួយនោះ នោះសាលាឧទ្ធរណ៍អាចសំរេចបានតែនៅក្នុងរង្វង់ដែលកំណត់ដោយបណ្តឹងឧទ្ធរណ៍នោះ ។

**មាត្រា ១៧៣.-**

បណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា នឹងចាត់ទុកជាបណ្តឹងទូទៅ កាលណារដ្ឋអាជ្ញាប្តឹងថា ទោសដែលកំណត់នោះស្រាលពេក ។

**មាត្រា ១៧៤.-**

ថ្វីត្បិតតែបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា មានអានុភាពទូលំទូលាយយ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍នោះអនុវត្តតែលើបណ្តឹងអាជ្ញាហើយមិនអាចមានអានុភាពទៅលើបណ្តឹងរដ្ឋប្បវេណីឡើយ ។

**មាត្រា ១៧៥.-**

សាលាឧទ្ធរណ៍មានសិទ្ធិកែប្រែបទល្មើស ដែលចៅក្រមជាន់ទីមួយបានសំរេច ប៉ុន្តែមិនត្រូវបញ្ចូនធាតុផ្សំថ្មីដែលចៅក្រមជាន់ទីមួយនោះពុំទាន់បានទទួលនិងជំនុំជំរះឡើយ ។

**មាត្រា ១៧៦.-**

បណ្តឹងឧទ្ធរណ៍ធ្វើដោយភាគីណាក៏ដោយ តាមគោលការណ៍ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីដែលចេញសាលក្រម ។ អ្នកប្តឹងឧទ្ធរណ៍ មិនចាំបាច់អោយដំណឹង នៃការប្តឹងរបស់ខ្លួននោះទៅភាគីផ្សេងទៀតទេ ។ ក្រឡាបញ្ជីត្រូវចុះបណ្តឹងឧទ្ធរណ៍ក្នុបញ្ជីមួយ ប្រើសំរាប់ចុះពាក្យបណ្តឹង ។ ក្រឡាបញ្ជី និងអ្នកប្តឹងត្រូវចុះហត្ថលេខាឬផ្តិតមេដៃលើបណ្តឹងដែលចុះក្នុងបញ្ជី ។ អ្នកប្តឹងឧទ្ធរណ៍អាចជំនួសបានដោយ អាជ្ញានុការី ដែលមានលិខិតប្រគល់សិទ្ធិពិសេស ។

**មាត្រា ១៧៧.-**

បណ្តឹងឧទ្ធរណ៍អាចធ្វើដោយសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតាបានដែរ ប៉ុន្តែសំបុត្រនេះ ត្រូវផ្ញើទៅការិយាល័យក្រឡាបញ្ជីនៃតុលាការនោះ ។ លិខិតនេះត្រូវមានបញ្ជាក់ច្បាស់អំពីឆន្ទះរបស់អ្នកប្តឹងឧទ្ធរណ៍ ។

**មាត្រា ១៧៨.-**

បណ្តឹងឧទ្ធរណ៍អាចធ្វើបានក្នុងរយៈពេលពីរខែ ។ កាលណាសាលក្រមត្រូវបានសំរេច ដោយចំពោះមុខរយៈពេលនេះចាប់ផ្តើមពីថ្ងៃប្រកាសសាលក្រម ។ កាលណាសាលក្រមសំរេចដោយកំបាំងមុខរយៈវេលាត្រូវគិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់ ។

ភាគីមិនចូលខ្លួនអាចប្តឹងឧទ្ធរណ៍បានមុនផុតរយៈពេលនៃការប្តឹងជំទាស់ ។

**មាត្រា ១៧៩.-**

ក្នុងរយៈពេលឧទ្ធរណ៍ និងក្នុងរយៈពេលជំនុំជំរះឧទ្ធរណ៍ ការអនុវត្តសាលក្រមរបស់តុលាការថ្នាក់ក្រោមត្រូវផ្អាកសិន។

**មារត ១៨០.-**

សម្រេង់នៃបណ្តឹងឧទ្ធរណ៍ សម្រង់សាលក្រម សំណុំរឿង និងបណ្តឹងដែលអ្នកប្តឹងឧទ្ធរណ៍ យល់ឃើញថាត្រូវដាក់បន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ត្រូវបញ្ជូនទាំងអស់មកការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ក្នុងរយៈយ៉ាងខ្លីបំផុត ។ បន្ទាប់មក ប្រធានសាលាឧទ្ធរណ៍បញ្ជូនសំណុំរឿងមកអគ្គរដ្ឋអាជ្ញា ដើម្បីអោយអគ្គរដ្ឋ-អាជ្ញាអាចធ្វើការសន្និដ្ឋាននៅពេលសវនាការបាន ។

**មាត្រា ១៨១.-**

ប្រសិនបើជនដែលតុលាការផ្តន្ទាទោសនោះត្រូវចាប់ខ្លួនជននោះត្រូវបញ្ជូនខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់រដ្ឋអាជ្ញា ឬរបស់ចៅក្រមពីមន្ទីរឃុំឃាំងខេត្ត-ក្រុងសាមី មកមន្ទីរឃុំឃាំងភ្នំពេញ ។

**មាត្រា ១៨២.-**

សាលដីការកំបាំងមុខសំរេចលើបណ្ដឹងឧទ្ធរណ៍ អាចប្ដឹងជំទាស់បានតាមនីតិវិធីប្ដឹងជំទាស់ក្នុងទំរង់បែបបទ និងក្នុងរយៈកាលដូចសាលក្រមសំរេចសេចក្ដីកំបាំងមុខដោយតុលាការព្រហ្មទណ្ឌខេត្ត ក្រុងដែរ ។

**មាត្រា ១៨៣.-**

បណ្ដឹងជំទាស់ លើការកោះហៅអោយចូលខ្លួនទៅសវនាការនៅពេលខាងមុខ ។ បើកាលណាអ្នកប្ដឹងជំទាស់ពុំបានចូលខ្លួនទេនោះសាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីលើកទីពីរ ហើយដែលសំរេចកំបាំងមុខ ទុកជាចំពោះមុខ មិនអាចនឹងប្ដឹងជំទាស់បានទៀតទេ លើកលែងតែប្ដឹងសាទុក្ខទៅតុលាការកំពូល ។

**មាត្រា ១៨៤.-**

របាយការណ៍ធ្វើដោយចៅក្រមម្នាក់របស់សាលាឧទ្ធរណ៍ មានកម្មវត្ថុបំភ្លឺជូនជាសាធារណៈអំពីឯកសារទាំងឡាយនៃរឿង ដើម្បីធ្វើឱ្យសមាសភាពក្រុមប្រឹក្សាជំនុំជំរះដែលនៅចំពោះមុខគូរភាគីបានដឹងមិនមែនគ្រាន់តែសាលក្រម ដែលត្រូវបានគេប្ដឹងឧទ្ធរណ៍នោះទេ ប៉ុន្តែដឹងអំពីធាតុផ្សំទាំងឡាយ ដែលបានដាក់ជូនឱ្យចៅក្រមជាន់ទីមួយពិនិត្យ និងសំរេច ។

ការបំពេញបែបបទខាងលើនេះ ត្រូវកត់ត្រាចូលក្នុងសាដីកា បើពុំនោះទេត្រូវទុកជាមោឃៈ ។

**មាត្រា ១៨៥.-**

ប្រសិនបើសាលាឧទ្ធរណ៍បង្គាប់អោយចៅក្រមម្នាក់ក្នុងបណ្ដាចៅក្រមរបស់ខ្លួនធ្វើការស៊ើបអង្កេតបន្ថែមចៅក្រមនេះត្រូវធ្វើរបាយការណ៍ថ្មីមួយទៀត កាលណាការស៊ើបអង្កេតបន្ថែមបានធ្វើចប់ ។ របាយការណ៍នេះត្រូវដាក់មកក្នុងសំណុំរឿង ដែលសាលាឧទ្ធរណ៍នឹងលើកយកមកបើកសវនាការ បើពុំនោះទេត្រូវទុកជាមោឃៈ ។

**មាត្រា ១៨៦.-**

របាយការណ៍នេះត្រូវសរសេរជាលាយល័ក្ខអក្សរ ហើយត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ។

អ្នកប្ដឹងឧទ្ធរណ៍ត្រូវបានសួរចំលើយ ក្រោយពេលដែលរបាយការណ៍ខាងលើនេះ អានអោយស្ដាប់រួច ។ ក្នុងរឿងសាមញ្ញ របាយការណ៍នេះធ្វើដោយសង្ខេបក៏បាន ។ ប៉ុន្តែក្នុងរឿងស្មុគស្មាញរបាយការណ៍ត្រូវតែធ្វើឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យតុលាការអាចវិនិច្ឆ័យរឿង ដោយបានដឹងរឿងសព្វគ្រប់ ។

**មាត្រា ១៨៧.-**

ក្រោយពីស្ដាប់របាយការណ៍រួច សាលាឧទ្ធរណ៍ស្ដាប់ចំលើយរបស់ជនជាប់ចោទ និងអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ។ បន្ទាប់មកសាលាឧទ្ធរណ៍ស្ដាប់ចំលើយ របស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រសិនបើមាន ។

បើគូក្ដីមានអ្នកការពារសិទ្ធិ អ្នកការពារសិទ្ធិនេះ ត្រូវសន្និដ្ឋានការពារមុនតំណាងមហាអយ្យការមាន

មតិមួយក្នុងករណីភាគីប្តឹងឧទ្ធរណ៍ ។

ប្រសិនបើរដ្ឋអាជ្ញាជាអ្នកប្តឹងឧទ្ធរណ៍ តំណាងមហាអយ្យការត្រូវមានមតិមុនអ្នកការពារ ។ លំដាប់លំដោយខាងលើនេះ បើពុំធ្វើទេក៏មិននាំអោយមោឃភាពដែរ ។

**មាត្រា ១៨៨.**

របៀបរបបបង្ហាញភស្តុតាង ត្រូវធ្វើដូចរបៀបបង្ហាញភស្តុតាងនៅតុលាការខេត្ត-ក្រុងដែរ ។

**មាត្រា ១៨៩.**

សាលាឧទ្ធរណ៍អាចចាត់វិធានការស៊ើបអង្កេតទាំងឡាយបាន ដូចតុលាការខេត្ត-ក្រុង ដូចជាកោសល្យវិច័យចុះពិនិត្យដល់ទីកន្លែងប្រមូលភស្តុតាង... ។ល ។ដែលខ្លួនយល់ឃើញថា មានសារៈសំខាន់ដើម្បីបំភ្លឺតុលាការ ។

**មាត្រា ១៩០.**

ការលើកវត្ថុតាងមកបង្ហាញចំពោះមុខសាលាឧទ្ធរណ៍មិនជាការចាំបាច់ទេ កាលណាការបង្ហាញវត្ថុតាងនោះបានធ្វើត្រឹមត្រូវរួចម្តង ហើយនៅចំពោះមុខតុលាការជាន់ទីមួយ ។

**មាត្រា ១៩១.**

សាលាឧទ្ធរណ៍ មានឆន្ទានុសិទ្ធិដើម្បីស្តាប់ ឬមិនស្តាប់ជាថ្មីម្តងទៀត នូវចម្លើយសាក្សី ដែលត្រូវបានចៅក្រមជាន់ទីមួយស្តាប់រួចហើយ ។

សាលាឧទ្ធរណ៍អាចសំរេចថា ត្រូវស្តាប់ ឬមិនស្តាប់សាក្សីថ្មី ទោះជាជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ឬតំណាងមហាអយ្យការបានប្តឹងសុំឱ្យស្តាប់ក៏ដោយ ។ បើសាលាឧទ្ធរណ៍មិនយល់ព្រមតាម ពាក្យសុំខាងលើនេះទេ បានន័យថា បើសាលាឧទ្ធរណ៍យល់ឃើញថា សាក្សីថ្មីនោះពុំមានអ្វីនាំមកបំភ្លឺដល់ ការសួរដេញដោលទេ សាលាឧទ្ធរណ៍ត្រូវចេញសាលដីការប្រៀបមួយ បញ្ជាក់អំពីមូលហេតុខាងលើនេះ បើពុំនោះទេ ត្រូវចុះយោបល់របស់ខ្លួនក្នុងសាលដីកាស្ថាពរ ។

**មាត្រា ១៩២.**

សាលាឧទ្ធរណ៍មានសិទ្ធិបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម ជាលាយល័ក្ខអក្សរមួយទៀតបាន កាលណាខ្លួនយល់ឃើញថាការស៊ើបសួរដែលធ្វើរួចហើយនោះ នៅពុំទានគ្រប់គ្រាន់ទេ ។ ក្នុងករណីនេះសាលាឧទ្ធរណ៍ ចាត់តាំងសមាជិករបស់ខ្លួនម្នាក់ឱ្យទទួលការស៊ើបអង្កេតនេះ ។

ភារកិច្ច និងរបៀបរបបចាត់តាំងចៅក្រម ត្រូវធ្វើដូចភារកិច្ច និងរបៀបរបបចាត់តាំងចៅក្រមនៅជាន់ទីមួយដែរ ។ ចៅក្រមដែល ត្រូវបានចាត់ខាងលើនេះ ប្រសិនបើចាំបាច់អាចប្រគល់សិទ្ធិរបស់ខ្លួនទៅចៅក្រមថ្នាក់

ក្រោមទៀតបាន។

**មាត្រា ១៩៣.-**

ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ច្រើនព្រមៗគ្នា គឺបណ្តឹងរបស់រដ្ឋអាជ្ញា របស់ជនជាប់ចោទ មេធាវី ឬ របស់ដើមបណ្តឹងរដ្ឋប្បវេណី នោះត្រូវតំណាងមហាអយ្យការ ជាអ្នកសន្និដ្ឋានមុន ពីព្រោះរដ្ឋអាជ្ញាបានលើឡើងមកវិញគ្រប់ចំនុច នៃបណ្តឹងអាជ្ញា។

បើដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទប្តឹងឧទ្ធរណ៍ដូចគ្នា នោះដើមបណ្តឹងរដ្ឋប្បវេណីត្រូវឆ្លើយមុន ទើបជនជាប់ចោទឆ្លើយការពារខ្លួនជាខាងក្រោយ។

**មាត្រា ១៩៤.-**

សាលដីការទាំងឡាយត្រូវមានសំអាងហេតុ ប៉ុន្តែបើសាលាឧទ្ធរណ៍យល់ឃើញថា ត្រូវតម្កល់សេចក្តីសំរេចរបស់ចៅក្រមជាន់ទីមួយ ដោយផ្អែកលើសំអាងហេតុដែលមាននៅក្នុងសាលក្រម នោះសាលាឧទ្ធរណ៍ប្រកាសថា អនុម័តឯកភាពលើសំអាងហេតុនោះ ដោយឥតចាំបាច់លើកសំអាងហេតុ នោះមកសរសេរម្តងទៀតឡើយ។

នៅចំពោះមុខសាលាឧទ្ធរណ៍ បើមានការលើកឡើងអំពីអញ្ញត្រកម្មឬមានការសន្និដ្ឋានថ្មី សាលាជំរះក្តីនេះត្រូវសំរេចយ៉ាងច្បាស់លាស់អំពីអញ្ញត្រកម្ម និង សេចក្តីសន្និដ្ឋានដែលអាចអោយរឿងមានសភាពថ្មីមួយ ។

កាលណាសាលាឧទ្ធរណ៍សំរេចបដិសេធសាលក្រម ដែលត្រូវគេប្តឹងឧទ្ធរណ៍នោះ សាលាឧទ្ធរណ៍ត្រូវតែអោយយោបល់របស់ខ្លួន ដែលជាហេតុនាំអោយខ្លួនសំរេចនោះ ។

**មាត្រា ១៩៥.-**

ចំពោះការប្រកាស ការសរសេរភាពត្រឹមត្រូវតាមច្បាប់ ការចុះហត្ថលេខា និងការបកស្រាយសាលដីការនោះត្រូវយកនីតិក្រមប្រើសំរាប់ធ្វើសាលក្រមតុលាការព្រហ្មទណ្ឌខេត្ត-ក្រុង មកអនុវត្តកិច្ចការខាងលើនេះដូចគ្នា ។

**មាត្រា ១៩៦.-**

កាលណាសាលក្រមត្រូវបានបដិសេធ ពីព្រោះអង្គហេតុមិនចូលជាបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ សាលាឧទ្ធរណ៍សំរេចអោយជនជាប់ចោទរួចខ្លួនពីបទចោទ ។

**មាត្រា ១៩៧.-**

កាលណាសាលក្រមត្រូវបានទទួលការឯកភាព ហើយអង្គហេតុគួរអោយផ្តន្ទាទោសទៅជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ សាលាឧទ្ធរណ៍ត្រូវចេញដីការយកទណ្ឌិតទៅដាក់គុក ឬចេញដីកាចាប់ខ្លួនកាលណាកិច្ចការនេះកើតមាន ។

**មាត្រា ១៩៨.៱**

សាលាឧទ្ធរណ៍មានសិទ្ធិលើកករណីមកជំនុំជំរះផ្ទាល់ កាលណាខ្លួនបដិសេធសាលក្រមរបស់តុលាការជាន់ទីមួយ ។

បញ្ហានេះកើតមាន កាលណានៅក្នុងសាលក្រមដែលត្រូវគេប្តឹងឧទ្ធរណ៍មានការរំលោភ ឬមានការមិនធ្វើ មិនបំពេញទម្រង់ច្បាប់ដែលមិនអាចកែសំរួលបាន ហើយដែលមានមោឃភាព ឬកាលណាសាលក្រមនោះសំរេចដោយមានការខុសឆ្គងលើអញ្ញត្រកម្ម ឬឧប្បត្តិហេតុ ហើយជាអាទិ៍លើសមត្ថកិច្ចជំនាញ ។

**មាត្រា ១៩៩.៱**

កាលណារឿងពុំទាន់មូល សាលាឧទ្ធរណ៍ត្រូវចាត់ ឬបង្គាប់អោយចាត់វិធានការទាំងឡាយដែលមានប្រយោជន៍ ឬអោយធ្វើការអង្កេតស៊ើបសួរចាំបាច់ដើម្បីរកការពិត ។

**មាត្រា ២០០.៱**

សាលាឧទ្ធរណ៍នឹងអាចលើកករណីមកជំនុំជំរះផ្ទាល់បាន កាលណាខ្លួនសំរេចបដិសេធសាលក្រមទាំងស្រុង ។

**មាត្រា ២០១.៱**

សាលាឧទ្ធរណ៍មិនអាចលើកករណីមកជំនុំជំរះផ្ទាល់ទេកាលណាខ្លួនបដិសេធសាលក្រម របស់តុលាការខេត្ត-ក្រុង ដែលសំរេចដោយខុសឆ្គងថា ខុសសមត្ថកិច្ចរបស់ខ្លួន ពីព្រោះតុលាការជាន់ទីមួយមិនទាន់បានធ្វើចប់នៅឡើយ ។

**មាត្រា ២០២.៱**

សាលាឧទ្ធរណ៍មានសមត្ថកិច្ចផងដែរ :

១-ជំនុំជំរះបណ្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសំរេចរបស់រដ្ឋអាជ្ញាអមតុលាការយោធា និង រដ្ឋអាជ្ញាខេត្ត-ក្រុង ។

២-ជំនុំជំរះបណ្តឹងឧទ្ធរណ៍ ចំពោះគ្រប់សេចក្តីសំរេចរបស់ចៅក្រមជាន់ទីមួយ"ដីកា ឬសាលក្រម" ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្ន អោយនៅក្រៅឃុំបណ្តោះអាសន្ន ឬលើកលែងចោទប្រកាន់ ។

**មារត ២០៣.៱**

បើសាលាឧទ្ធរណ៍បដិសេធសេចក្តីសំរេចមិនចោទប្រកាន់ របស់រដ្ឋអាជ្ញា ឬសេចក្តីសំរេច លើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេត ក្នុករណីជនជាប់ចោទនៅក្រៅឃុំ សាលាឧទ្ធរណ៍អាចសំរេចអោយយកជននោះមកដាក់ឃុំជាបណ្តោះអាសន្ន ។ ដូចនេះ សាលាឧទ្ធរណ៍ត្រូវចេញដីការកចាប់ខ្លួន ។

សាលាឧទ្ធរណ៍បង្គាប់អោយបញ្ជូនជនជាប់ចោទទៅចំពោះមុខតុលាការសាមី កាលណាខ្លួនឃើញថា សំណុំរឿងមូលហើយ ។

**មាត្រា ២០៤.-**

កាលណាសាលាឧទ្ធរណ៍បដិសេធសេចក្តីសំរេចឃុំខ្លួនបណ្តោះអាសន្ន នោះសាលាឧទ្ធរណ៍ ត្រូវបង្គាប់ អោយដោះលែងជនជាប់ចោទនោះភ្លាម ។

**មាត្រា ២០៥.-**

កាលណាសាលាឧទ្ធរណ៍បដិសេធសេចក្តីសំរេចអនុញ្ញតអោយជនជាប់ចោទនៅក្រៅឃុំ នោះសាលា ឧទ្ធរណ៍ត្រូវបង្គាប់អោយចាប់ខ្លួនជននោះ មកឃុំជាបណ្តោះអាសន្ន ។ សាលាឧទ្ធរណ៍ចេញដីការកចាប់ខ្លួន ។

## ជំពូកទី ៧

## តុលាការកំពូល

**មាត្រា ២០៦.-**

តុលាការកំពូលតាំងនៅភ្នំពេញ ។

សមត្ថកិច្ចរបស់តុលាការកំពូលលាតសន្ធឹងទៅលើដែនដីទាំងមូល និងទៅលើគ្រប់សាលាជំរះក្តីនៃរដ្ឋ កម្ពុជា។

**មាត្រា ២០៧.-**

តុលាការកំពូលជំនុំជំរះអង្គច្បាប់ ឥតជំនុំជំរះលើអង្គហេតុទេ ។ ប៉ុន្តែ តុលាការកំពូលជំនុំជំរះ អង្គហេតុផងដែរក្នុងករណីមានបណ្តឹងសាទុក្ខលើកទីពីរ ក្នុងល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រាទាំងឡាយខាង ក្រោម ។

សេចក្តីសំរេចរបស់តុលាការកំពូល ជាសេចក្តីអធិបតេយ្យ មានន័យថា មិនអាចប្តឹងតវ៉ាបានឡើយ លើក លែងតែបណ្តឹងសើរើក្នុងករណីមួយចំនួនដែលមានកំណត់ក្នុងច្បាប់ ។

**មាត្រា ២០៨.-**

តុលាការកំពូលក្នុងពេលជំនុំជំរះរឿងព្រហ្មទណ្ឌ ក៏ដូចជារឿងរដ្ឋប្បវេណី ត្រូវមានប្រធាន នៃសាលាជំរះ ក្តីជាន់ខ្ពស់នេះ អមដោយចៅក្រម ៤ រូប មានតំណាងមហាអយ្យការ ១ រូប និង ក្រឡាបញ្ជី ១ រូប ។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានមួយរូបត្រូវទទួលការងារជំនួស ។

**មាត្រា ២០៩.-**

ករណីដែលបើកអោយតុលាការកំពូលសំរេចបដិសេធនោះគឺ :

១-សមាសភាពនៃសាលាជំរះក្តីមិនត្រឹមត្រូវតាមច្បាប់ ដោយគ្មានចំនួនចៅក្រមគ្រប់គ្រាន់ក្តី ដោយមានហេតុដទៃទៀតក្តីដែលកើតចេញពីការមិនគោរពបញ្ញត្តិច្បាប់ ។

២-ការបំពាន ឬការខ្វះចន្លោះមិនបានបំពេញនូវទំរង់ច្បាប់ ដែលច្បាប់ចាត់ទុកជាមោឃៈ ដូចជាសាវនាការមិនបានធ្វើជាសាធារណៈ ។

៣-ការប្រកែក ឬការខ្វះខាតមិនបានសំរេចលើពាក្យសុំ ឬសេចក្តីសន្និដ្ឋានមួយ ឬច្រើនរបស់ភាគីណាមួយ រួមមានអយ្យការផងដែលប្រើសិទ្ធិឬសេរីភាពរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ ឬដែលច្បាប់ប្រគល់អោយ ។

៤-អសមត្ថកិច្ច

៥-ការគ្មានសំអាងហេតុ ឬភាពផ្ទុយរវាងសំអាងហេតុ និងសេចក្តីសំរេច

៦-ការបំពាន ឬការអនុវត្តខុសច្បាប់នៃអង្គសេចក្តី

៧-ការបំពានអត្ថន័យនៃអង្គហេតុ

៨-ការរំលោភលើអំណាច ។

**មាត្រា ២១០.-**

នៅគ្រប់ករណីទាំងអស់ បណ្តឹងសាទុក្ខត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលចេញសេចក្តីសំរេច ។ បណ្តឹងសាទុក្ខនេះត្រូវចុះក្នុងបញ្ជីនៅក្នុងការិយាល័យក្រឡាបញ្ជីនៃសាលាជំរះក្តីសាមី ។

**មាត្រា ២១១.-**

បណ្តឹងសាទុក្ខត្រូវធ្វើដោយផ្ទាល់ ដោយអ្នកមានប្រយោជន៍នៃរឿងក្តី ឬដោយតតីជន ដែលបានទទួលអំណាចជាលាយល័ក្ខអក្សរពិសេស ឬដោយបុគ្គលដែលច្បាប់ទទួលស្គាល់ ជាតំណាងត្រឹមត្រូវតាមច្បាប់ ដូចជាឪពុកតំណាងឱ្យកូនជាអនីតិជនជាដើម ។

**មាត្រា ២១២.-**

បណ្តឹងសាទុក្ខដាច់ខាតត្រូវមានហត្ថលេខារបស់អ្នកមានប្រយោជន៍ ឬអ្នកតំណាងរបស់គេ និងហត្ថលេខារបស់ក្រឡាបញ្ជី ។កាលបរិច្ឆេទត្រូវតែចុះ ។ បើសាមីខ្លួនមិនចេះចុះហត្ថលេខា អ្នកនោះត្រូវផ្តិតមេដៃ ។

ប៉ុន្តែបើគ្មានហត្ថលេខារបស់ក្រឡាបញ្ជី ឬបើគ្មានកាលបរិច្ឆេទ បណ្តឹងសាទុក្ខក៏ត្រូវតែទទួលបានដែរ ប្រសិនបើគ្មានការលួចបន្លំអ្វីទេ ប៉ុន្តែត្រូវពិន័យប្រាក់ចំនួន ៥.០០០រៀល ទៅលើក្រឡាបញ្ជី ។ ប្រាក់ពិន័យនេះត្រូវសំរេចដោយតុលាការកំពូលក្នុងសាលដីការបស់ខ្លួន ទោះបីបណ្តឹងសាទុក្ខនោះត្រូវបដិសេធ ដោយខុសនឹងទម្រង់ច្បាប់ក៏ដោយ ។

**មាត្រា ២១៣.-**

ក្រោយពីបណ្តឹងសាទុក្ខត្រូវបានទទួលដោយក្រឡាបញ្ជីនៃសាលាជំរះក្តីដែលបានជំនុំជំរះរឿងនោះ ក្រឡាបញ្ជីនោះត្រូវប្រញាប់ប្រញាល់រៀបសំណុំរឿងអោយបានត្រឹមត្រូវ ហើយបញ្ជូនសំណុំរឿងនោះមកប្រធានតុលាការកំពូល ។

**មាត្រា ២១៤.-**

នៅពេលដែលសំណុំរឿងបានមកដល់ដៃខ្លួនហើយ ប្រធានតុលាការកំពូលបង្គាប់ឱ្យយកសំណុំរឿងនោះទៅចុះតាមលេខរៀង នៅការិយាល័យក្រឡាបញ្ជីនៃតុលាការកំពូល ។

ក្រឡាបញ្ជីត្រូវឱ្យដំណឹងភ្លាមទៅម្ចាស់បណ្តឹសាទុក្ខថា ក្នុងរយះពេលម្ភៃថ្ងៃ គិតពីថ្ងៃទទួលដំណឹង ត្រូវធ្វើសារណាមួយជូនដល់ប្រធានតុលាការកំពូល ហើយក្នុងសារណានោះខ្លួនត្រូវប្រាប់អំពីមធ្យោបាយទាំងឡាយការពារខ្លួនតាមផ្លូវច្បាប់ ។

កាលណាបណ្តឹងសាទុក្ខជារបស់អគ្គរដ្ឋអាជ្ញាសេចក្តីសន្និដ្ឋានលើកឡើងរាល់ចំណុចច្បាប់ ត្រូវតែធ្វើជូនតុលាការជាចាំបាច់ ។

បើម្ចាស់បណ្តឹងសាទុក្ខមិនប្រើសិទ្ធិរបស់ខ្លួន ក្នុងរយៈពេលដូចបានកំណត់ខាងលើនេះទេ ប្រធានតុលាការកំពូលបញ្ជូនសំណុំរឿងអោយចៅក្រមម្នាក់របស់ខ្លួនធ្វើរបាយការណ៍ ។ បើសិនម្ចាស់បណ្តឹងសាទុក្ខធ្វើសារណាក្រឡាបញ្ជាីត្រូវជូនដំណឹងអំពីសារណានេះដល់ភាគីម្ខាងទៀត ដែលមានរយៈពេលម្ភៃថ្ងៃដែរដើម្បីឆ្លើយតបវិញ ។

ដំណឹងដដែលនោះ ក៏ត្រូវជូនដល់មេធាវីជាដាច់ខាតដែរ ។មេធាវីអាចចាត់ការពិនិត្យបណ្តឹងសាទុក្ខនៅការិយាល័យក្រឡាបញ្ជីតុលាការកំពូល ក្រោយពេលបានចុះហត្ថលេខាលើបណ្តឹងសាទុក្ខ ។

សំណុំរឿងត្រូវទុកនៅការិយាល័យក្រឡាបញ្ជី ដើម្បីអោយមេធាវីចាត់ការអោយលេខាធិការរបស់ខ្លួនចម្លងតាមត្រូវការ ។

ទម្រង់បែបបទខាងលើនេះ បើមិនធ្វើតាមទេ ត្រូវទុកជាមោឃៈ ។ ភាគីរងគ្រោះដោយការខ្វះខាតខាងលើនេះ អាចសុំអោយចាត់នីតិវិធីសារឡើងវិញ ពីទម្រង់ដែលខ្វះខាតនោះ ។

ការណាខ្លួនឃើញថា រយៈពេលដែលកំណត់ខាងលើមិនគ្រប់គ្រាន់ ម្ចាស់បណ្តឹងសាទុក្ខចុងចម្លើយឬមេធាវីរបស់គេ អាចសុំពន្យាររយៈពេលខាងលើនេះបានដប់ថ្ងៃទៀត ។ ពាក្យសុំពន្យាពេលអាចធ្វើជាលិខិតធម្មតា យកមកដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការកំពូល ។

ផុតរយៈពេលអោយធ្វើសារណាតប ទោះចុងចម្លើយធ្វើ ឬមិនធ្វើសារណាតបក៏ដោយ ប្រធានតុលាការកំពូលបញ្ជូនសំណុំរឿងអោយចៅក្រមរបស់ខ្លួនធ្វើរបាយការណ៍ ។

**មាត្រា ២១៥.-**

របាយការណ៍របស់ចៅក្រមត្រូវអធិប្បាយអំពីៈ

-អង្គហេតុ និងដំណើរការនៃនីតិវិធី

-សេចក្តីសង្ខេបដោយឥតលំអៀង ស្តីពីធាតុផ្សំដាក់បន្ទុក និងធាតុផ្សំដោះបន្ទុក ព្រមទាំងឆ្លើយគ្រប់ចំណុចច្បាប់ដែលភាគីបានលើក ។ របាយការណ៍ក៏ត្រូវចង្អុលប្រាប់ដែរនូវការដោះស្រាយផ្សេងៗ ដែលតុលាការកំពូលអាចធ្វើបានចំពោះបញ្ហាគតិយុត្តិ ។

របាយការណ៍នេះ ត្រូវដាក់ចូលជាឧបសម្ព័ន្ធទៅក្នុងសំណុំរឿង ដែលត្រូវបញ្ជូនទៅអគ្គរដ្ឋអាជ្ញា ដើម្បីធ្វើការសន្និដ្ឋាន ។ សេចក្តីសន្និដ្ឋានរបស់អគ្គរដ្ឋអាជ្ញា ឬរបស់អគ្គរាជ្ញារង ដែលចាត់ការក្នុងនាមអគ្គរដ្ឋអាជ្ញាត្រូវតែមានជាដាច់ខាតក្នុងរឿងនីមួយៗ ។ សេចក្តីសន្និដ្ឋាននេះអាចធ្វើដោយមាត់ទទេ ក្នុងពេលសវនាការក៏បាន ។ ប៉ុន្តែចំពោះបញ្ហាគតិយុត្តិទាំងឡាយណាដែលមានសារៈសំខាន់នោះទាមទារត្រូវតែអោយធ្វើជាលាយលក្ខណ៍អក្សរ ។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវបានបញ្ចូលក្នុងសំរឿងមុនពេលបើកសវនាការ ។

**មាត្រា ២១៦.-**

ក្រោយពីបានពិនិត្យសំនុំរឿងរួចហើយ អគ្គរដ្ឋអាជ្ញាបញ្ជូនសំនុំរឿងនោះមកប្រធានតុលាការកំពូលវិញ។ សំនុំរឿងនោះត្រូវបានចុះក្នុងបញ្ជីជំនុំជំរះក្នុងពេលសវនាការនាពេលខាងមុខដ៏សមគួរ។

ការសួរដេញដោល ត្រូវធ្វើក្នុងសវនាការសាធារណៈ។ ចៅក្រមរបាយការណ៍ ត្រូវអានរបាយការណ៍របស់ខ្លួនមុនគេ។ បន្ទាប់មកតំណាងមហាអយ្យការធ្វើការសន្និដ្ឋាន ហើយជាបន្តបន្ទាប់ទៀតនោះ គឺម្ចាស់បណ្តឹងសាទុក្ខចុងចម្លើយ ហើយនិងមេធាវីរបស់គេ។

លុះការសួរដេញដោល បានចប់សព្វគ្រប់ តុលាការថយទៅពិភាក្សាក្នុងបន្ទប់ពិភាក្សា និងសរសេរសាលដីកា។ សាលដីការត្រូវ ប្រកាសនៅពេលសវនាការនោះតែម្តងក៏បាន ឬប្រកាសនៅពេលសវនាការណាមួយដែលតុលាការកំពូលកំនត់ក៏បាន។

ក្នុងករណីណាក៏ដោយ តុលាការកំពូលមិនអាចចូលពិភាក្សាលើរឿងណាមួយ ហើយចេញសាលដីកាបានទេ កាលណាការសួរដេញដោយមិនទាន់បានធ្វើក្នុងសវនាការសាធារណៈនៅឡើយ។ គូភាគីទាំងអស់អាចពឹងមេធាវី ឬដាក់សារណាថ្មីរបស់ខ្លួនជូនតុលាការកំពូលជានិច្ច បើខ្លួនយល់ថា មានចំណុចច្បាប់ថ្មីដែលគួរលើកកាលណាការសួរដេញដោលមិនទាន់ប្រកាសបិទទេនោះ ។រីឯសិទ្ធឆ្លើយតបក៏ត្រូវតែគោរព្វជានិច្ច ។

**មាត្រា ២១៧.-**

បណ្តឹងសាទុក្ខ និងរយៈពេលសំរាប់ប្តឹងសាទុក្ខមានអានុភាពផ្អាក ។ដូចនេះ ការអនុវត្តសាលដីកា

សាលាឧទ្ធរណ៍ត្រូវផ្អាកសិនក្នុងរយៈពេលប្តឹងសាទុក្ខ ហើយបើសិនមានបណ្តឹងសាទុក្ខនៅក្នុងរយៈពេលបណ្តឹងសាទុក្ខ ត្រូវផ្អាករហូតដល់ថ្ងៃចេញសាលដីការបស់តុលាការកំពូល ។

**មាត្រា ២១៨.-**

បណ្តឹងសាទុក្ខក៏មានអានុភាពផ្ទេរសមត្ថកិច្ចដែរ មានន័យថា បណ្តឹងសាទុក្ខលើកអ្វីៗ ទាំងអស់នៅក្នុងសេចក្តីសំរេចជាប់បណ្តឹងមកជូនតុលាការកំពូល លើកលែងតែភាគីប្តឹងសាទុក្ខច្បាស់លាស់ទៅលើភាគណាមួយនៃសាលដីកា ។ ក្នុងករណីខាងក្រោយនេះតុលាការកំពូលទទួលជំនុំជំរះតែក្នុងវិធានការបញ្ជាក់ច្បាស់ក្នុងបណ្តឹងសាទុក្ខ ។ សេចក្តីកំរិតកំណត់នេះ ត្រូវចុះក្នុងបញ្ជីតំកល់នៅការិយាល័យក្រឡាបញ្ជីនៅពេលប្តឹងសាទុក្ខ ។

**មាត្រា ២១៩.-**

តាមគោលការណ៍ តុលាការកំពូលត្រូវជំនុំជំរះក្នុងរយៈវេលាបីខែយ៉ាងយូរ គិតពីថ្ងៃទទួលសំណុំរឿងនិងឯកសារសំអាងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការកំពូល ។

**មាត្រា ២២០.-**

សាលដីការបស់តុលាការកំពូល ត្រូវតែមានសំអាងហេតុដាច់ខាត ឬមួយក៏សាលាជំរះក្តីនេះបដិសេធសេចក្តីសំរេច ដែលត្រូវគេប្តឹងសាទុក្ខ ឬមួយក៏តុលាការកំពូលបដិសេធចោលនូវបណ្តឹងសាទុក្ខ ឬមួយក៏តុលា-ការកំពូលចេញសេចក្តីសំរេចរបស់ខ្លួនជំនួសសេចក្តីសំរេចដែលត្រូវគេប្តឹងក្រោយពីមានបណ្តឹងសាទុក្ខលើកទីពីរ ។

ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធចោល សេចក្តីសំរេចដែលត្រូវគេប្តឹងសាទុក្ខនេះមានអំណាចនិង មានកំលាំងយកទៅអនុវត្តបាន ។ ភាគីដែលបណ្តឹងសាទុក្ខរបស់ខ្លួនត្រូវបដិសេធចោល មិនអាចប្តឹងសាទុក្ខបានទៀតឡើយ ចំពោះសាលដីកាដដែលនោះ ទោះលើកយកលេសឬមធ្យោបាយអ្វីមកសំអាងក៏ដោយ លើកលែងតែករណីដែលមានចែងក្នុងមាត្រាខាងក្រោមទាក់ទងនឹងបណ្តឹងសើរើវិញ ។

**មាត្រា ២២១.-**

ប្រសិនបើសាលដីកាត្រូវបានបដិសេធទាំងមូល ក្រោយពីមានបណ្តឹងសាទុក្ខលើគ្រប់ចំនុចសាលដីកាតុលាការកំពូល ដាក់គូភាគីក្នុងសភាពមុនពេលចេញសេចក្តីសំរេច ដែលត្រូវបានបដិសេធនោះ ហើយប្រគល់រឿងទៅឱ្យសាលាជំរះក្តីដដែលជំនុំជំរះ ប៉ុន្តែដោយមានសមាសភាពផ្សេង ។

ប្រសិនបើការបដិសេធមាននៅលើបណ្តឹងសាទុក្ខ ដែលប្តឹងតែទៅលើចំណុចខ្លះ នៃសេចក្តីសំរេចនៃតុលាការថ្នាក់ក្រោម នោះចំនុចឯទៀតត្រូវនៅមានតម្លៃដដែល ហើយការបដិសេធ និងការបង្វិលឱ្យទៅជំនុំជំរះវិញត្រូវធ្វើតែទៅលើចំនុច ដែលមានក្នុងកម្មវត្ថុនៃបណ្តឹងសាទុក្ខ ។

ប៉ុន្តែក្នុងករណីបណ្តឹងសាទុក្ខមានកំរិត តុលាការកំពូលអាចពិនិត្យមោឃភាពនៃសេចក្តីសំរេចទាំងស្រុង

បានកាលបើមោឃភាពនៃចំណុចប្ដឹងសារទុក្ខនោះ បណ្ដាលឱ្យមានមោឃភាព លើសេចក្ដីសំរេចទាំងមូល ។

**មាត្រា ២២២.-**

កាលណាអង្គហេតុមិនចូលជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុទេ តុលាការកំពូលគ្រាន់តែប្រកាសថាគ្មានបទល្មើសព្រហ្មទណ្ឌសំរេចឱ្យជនជាប់ចោទរួចខ្លួន ហើយទុកឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទៅសាលាជំរះក្ដីរដ្ឋប្បវេណី បើសិនជាខ្លួនចង់ប្ដឹង។

**មាត្រា ២២៣.-**

តុលាការកំពូលអាចសំរេចដកសេចក្ដីខ្លះ ដោយឥតបង្វិលសំណុំរឿងទៅសាលាជំរះក្ដីថ្នាក់ក្រោម ដូចជាក្នុងករណីអនុវត្តដោយ ភ័ន្តច្រឡំនូវអនុទោស ឬម្យ៉ាងទៀតការព្យួរទោសមិនត្រូវអនុញ្ញាតឱ្យ ប៉ុន្តែសាលាជំរះក្ដីថ្នាក់ក្រោមត្រឡប់ជាអនុញ្ញាតឱ្យទៅវិញ ។

**មាត្រា ២២៤.-**

បើតុលាការកំពូលឃើញថា ការជំនុំជំរះមុននោះត្រឹមត្រូវហើយ ប៉ុន្តែអំពើប្រព្រឹត្តនោះ មិនចូលជាបទ-ល្មើសដូចបានលើកនោះទេ គឺវាជាបទល្មើសមួយទៀតដែលត្រូវផ្ដន្ទាទោសប៉ុនគ្នានោះ តុលាការកំពូលអាចសំរេចមិនបដិសេធទេ គឺគ្រាន់តែកែប្រែបទល្មើសដោយតម្កល់ចំនួនទោស និងចំនួនសំណងជំងឺចិត្តនៅដូចដើម ។

**មាត្រា ២២៥.-**

ក្នុងករណីតុលាការកំពូលឃើញថា អង្គហេតុត្រូវចូលជាបទល្មើសមួយ ដែលត្រូវផ្ដន្ទាទោសខ្ពស់ជាងឬទាបជាងនោះតុលាការកំពូលចាំបាច់ត្រូវបដិសេធនឹងបង្វិលរឿងទៅសាលាជរះក្ដីដដែល ដើម្បីជំនុំជរះដោយមានសមាសភាពផ្សេងៗ ឬទៅសាលាជរះក្ដីមានសមត្ថកិច្ចណាមួយ ។

**មាត្រា ២២៦.-**

ដើម្បីជៀសវាងកុំឱ្យមានការបន្លាយនីតិវិធីដោយឥតប្រយោជន៏ តុលាការកំពូលអាចជំនុំជំរះរួមក្រុមលើអង្គហេតុ និងអង្គច្បាប់រួចចេញសាលដីកាស្ថាពរ ក្រោយពីបានទទួលបណ្ដឹងសាទុក្ខរបស់តំណាងមហាអយ្យការរបស់ទណ្ឌិត ឬរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវីរបស់គេ កាលបើសាលាជំរះក្ដីថ្នាក់ក្រោមមិនគោរពតាមសាលដីកាទីមួយដែលសំរេចបដិសេធ និងបង្វិលសំណុំរឿងទៅតុលាការថ្នាក់ក្រោមនោះ ។

សមាសភាពរួមក្រុមត្រូវមានចៅក្រមចំនួនប្រាំបួនរូប រួមមានទាំងប្រធានពេញសិទ្ធិនៃតុលាការកំពូលផងដែលជាប្រធាន ។ ក្នុងករណីប្រធានតុលាការកំពូលជាប់រវល់ អនុប្រធានតុលាការកំពូលម្នាក់ចូលរួមជំនួស ។ ក្នុងសមាសភាពរួមក្រុមនៃតុលាការកំពូលពុំមានបែងចែករវាងចៅក្រមដែលបានធ្វើរឿងហើយនាពេលពិនិត្យបណ្ដឹងសាទុក្ខទីមួយ និងចៅក្រមដែលពុំទាន់បានធ្វើរឿងនោះសោះ ប៉ុន្តែមិនអាចចូលរួមក្នុងសមាសភាពនៃ

តុលាការកំពូលបានឡើយ ចំពោះចៅក្រមទាំងឡាយដែលបានធ្វើរឿងនោះក្នុងឋានៈផ្សេងៗទៀត ។

**មាត្រា ២២៧.-**

តុលាការកំពូលក៏មានសមត្ថកិច្ចពិសេសមួយទៀតដែរ ដើម្បីជំនុំជំរះរួមក្រុមបណ្តឹងសើរើ ។

**មាត្រា ២២៨.-**

ការជំនុំជំរះលើបណ្តឹងសើរើជានីតិវិធីតវ៉ាមួយ មិនសុខចិត្តនឹងសាលក្រមឬសាលដីកាដែលទៅជាសាលក្រម ឬសាលដីការស្ថាពរហើយនោះហើយដែលមានអំណាចដាច់ខាតទៅហើយ ។

នីតិវិធីជំនុំជំរះលើបណ្តឹងសើរើនេះ មានទិសដៅតែមួយគត់គឺកំណត់ភាពសុច្ចរិតស្លូតត្រង់របស់ទណ្ឌិតឡើងវិញ ។

**មាត្រា ២២៩.-**

បណ្តឹងសើរើអាចធ្វើបានក្នុងរឿងព្រហ្មទណ្ឌ ទោះជាសាលាជំរះក្តីណាជំរះសេចក្តីក៏ដោយហើយទោះជាទោសដែលសំរេចនោះប៉ុណ្ណាក៏ដោយ ។

**មាត្រា ២៣០.-**

អាចប្តឹងឱ្យជំនុំជំរះសើរើបាន ក្នុងករណីខាងក្រោមនេះ:

១- កាលណាក្រោយពីការផ្តន្ទាទោសពីបទធ្វើមនុស្សឃាដ ស្រាប់តែមានភស្តុតាងបញ្ជាក់ឱ្យឃើញច្បាស់លាស់ថា ជនរងគ្រោះមានជីវិតនៅឡើយ ។

២- កាលណាក្រោយពីការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមស្រាប់តែមានសាលដីកា ឬសាលក្រមថ្មីមួយទៀតសំរេចផ្តន្ទាទោសជនជាប់ចោទម្នាក់ទៀតចំពោះអង្គសេចក្តីដដែល ដោយគ្មានអ្វីបញ្ជាក់ថា រវាងអ្នកទាំងពីរមានការសមគំនិត ឬសហការអ្វីឡើយហើយការផ្តន្ទាទោសទាំងពីរនេះពុំមានទាក់ទងគ្នាឡើយ ។

ភាពផ្ទុយគ្នានេះជាភស្តុតាងនៃភាពសុច្ចរិតស្លូតត្រង់របស់ទណ្ឌិតណាមួយក្នុងបណ្តាទណ្ឌិតទាំងពីរ ។

៣- កាលណាសាក្សីណាមួយត្រូវបានតុលាការយកចំលើយរួចហើយ ហើយក្រោយមកសាក្សីនោះត្រូវបានតុលាការផ្តន្ទាទោសដាក់គុកក្នុងរឿងធ្វើសាក្សីទុច្ចរិតដាក់បន្ទុកលើជនជាប់ចោទហើយ បើគ្មានចំលើយសាក្សីទុច្ចរិតនោះទេនោះភាពសុច្ចរិតស្លូតត្រង់នៃទណ្ឌិតត្រូវតែមាន ។

៤- កាលណាក្រោយពីការផ្តន្ទាទោសព្រហ្មទណ្ឌ អង្គហេតុថ្មីបានកើតមាន ឬកាលណាវត្ថុទាំងនេះជាហេតុនាំឱ្យបញ្ជាក់បាននូវភាពសុច្ចរិតស្លូតត្រង់របស់ទណ្ឌិត ។

**មាត្រា ២៣១.-**

ក្នុងគ្រប់ករណីទាំងអស់ អ្នកដែលមានសិទ្ធិប្តឹងសុំឱ្យជំនុំជំរះសើរើបាននោះគឺ :

១- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២- ទណ្ឌិត ឬតំណាងពេញច្បាប់របស់ទណ្ឌិតក្នុងករណីទណ្ឌិតអសមត្ថភាព

៣- សាហព័ន្ធ ឪពុកម្តាយ កូន របស់ទណ្ឌិត និយាយរួមជនដែលមានប្រយោជន៍ខាងផ្នែកសម្ភារៈ ឬខាងផ្លូវចិត្តកាលណាទណ្ឌិតនោះស្លាប់ ឬបាត់ខ្លួន ។

**មាត្រា ២៣២.-**

ក្រោយពីបានទទួលដំណឹងសើរើតុលាការកំពូលត្រូវសំរេចសេចក្តីរួមក្រុម អំពីការផ្អាកការអនុវត្តសាលក្រម ឬសាលដីកាដែលត្រូវគេប្តឹងសើរើក្នុងរយៈពេល៨ថ្ងៃយ៉ាងយូរ ក្រោយពីថ្ងៃទទួលបណ្តឹងដោយចេញសាលដីកាមានមូលហេតុច្បាស់លាស់ ។ បណ្តឹងសើរើមានអានុភាព នាំឱ្យលើករឿងទាំងអស់ឱ្យតុលាការកំពូលជំនុំជំរះ ។

**មាត្រា ២៣៣.-**

បន្ទាប់មក ប្រធានតុលាការកំពូលចាត់ការឱ្យក្រឡាបញ្ជីជូនដំណឹងដល់ម្ចាស់បណ្តឹង និងមេធាវីប្រសិនបើមាន ។ ម្ចាស់បណ្តឹងមានថិរវេលាសាមសិបថ្ងៃគិតពីថ្ងៃទទួលបណ្តឹង ដើម្បីបំពេញបណ្តឹងរបស់ខ្លួនតាមការគួរ ។

មេធាវីដែលត្រូវចាត់តាំងលើបណ្តឹងសុំជំនុំជំរះសើរើត្រូវបានទទួលដំណឹងដូចម្ចាស់បណ្តឹងដែរ ហើយអាចចាត់ការឱ្យលេខាធិការមកចម្លងសំណុំរឿងនៅការិយាល័យក្រឡាបញ្ជី ។

ក្រោយពីផុតរយៈពេលសាមសិបថ្ងៃទុកសំរាប់ម្ចាស់បណ្តឹង និងមេធាវីរបស់គេ ប្រធានតុលាការកំពូលបញ្ជូនសំណុំរឿង និងវត្ថុតាងទាំងអស់ ព្រមទាំងពាក្យសុំជំនុំជំរះសើរើទៅជូនអគ្គរដ្ឋអាជ្ញាដែលត្រូវធ្វើសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរក្នុងរយៈពេលសាមសិបថ្ងៃ ។

ទម្រង់បែបបទខាងលើនេះ បើមិនបំពេញបានទេត្រូវទុកជាមោឃៈ ។

ក្នុងពេលសំណុំរឿងត្រឡប់មកពីអគ្គរដ្ឋអាជ្ញាវិញ ប្រធានតុលាការកំពូលចាត់តាំងចៅក្រមមួយរូបឱ្យធ្វើរបាយការណ៍គ្រប់កាលៈទេសៈនៃរឿង ។

នៅពេលសវនាការក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រម សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចំលើយរបស់អ្នកប្តឹង និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីសំណុំរឿងត្រូវបានដាក់ពិភាក្សារួច តុលា-ការកំពូលសំរេចចេញសាលដីការរបស់ខ្លួន ។

ក្នុងករណីណាក៏ដោយតុលាការកំពូលមិនត្រូវពិភាក្សារឿង ឬសរសេរសេចក្តីព្រាងសាលដីការមុនពេលដែលរឿងត្រូវបានដាក់សួរដេញដោលក្នុងសាវនាការសាធារណៈសោះឡើយ ។

**មាត្រា ២៣៤.-**

បើតុលាការកំពូលយល់ឃើញថា រឿងមូលហើយ តុលាការកំពូលជំនុំជំរះរួមក្រុមសាឡើងវិញ រីឯសាលដីការនោះជាសាលដីការស្ថាពរ ។ ផ្ទុយទៅវិញតុលាការកំពូលអាចសំរេចឱ្យស៊ើបអង្កេតបន្ថែមដល់អង្គសេចក្តី ដោយចាត់ក្រុមប្រឹក្សា ចៅក្រម ឬចៅក្រមនៃតុលាការកំពូល ឬក្នុងករណីពិសេស ដោយចាត់ចៅក្រមស៊ើបសួរនៃសាលាជរះក្តីថ្នាក់ក្រោម ។

តុលាការកំពូល ត្រូវឱ្យដំណឹងដល់ម្ចាស់បណ្តឹងសើរើ និងមេធាវីរបស់គេអំពីអ្វី១ ដែលជាពតិមានប្រមូលបានក្នុងការចាត់ការបន្ថែមនេះ ។

មេធាវីអាចចាត់លេខាធិការរបស់ខ្លួនឱ្យមកចម្លងឯកសារទាំងនោះបាន ។

លុះការស៊ើបអង្កេតបន្ថែមនេះបានចប់សព្វគ្រប់ហើយ ប្រធានតុលាការកំពូលចាត់ការឱ្យដាក់រឿងជំនុំជរះក្នុងសវនាការសាធារណៈ ស្តាប់សាឡើងវិញ នូវរបាយការណ៍របស់ចៅក្រម សេចក្តីសន្និដ្ឋានរបស់ តំណាងមហាអយ្យការ ចំលើយរបស់ម្ចាស់បណ្តឹងសើរើ និងសេចក្តីសន្និដ្ឋានមេធាវីរបស់គេ ។

សាលដីកាត្រូវប្រកាសជាសាធារណៈ ។

**មាត្រា ២៣៥.\-**

ការអនុគ្រោះទោស និងការលើកលែងទោសជាទូទៅដែលបានសំរេចហើយពុំមានជាឧបសគ្គដល់បណ្តឹងឱ្យជំនុំជំរះសើរើឡើយ ។

**មាត្រា ២៣៦.\-**

សាលដីការរបស់តុលាការកំពូលដែលសំរេចថា ទណ្ឌិតជាជនស្លូតត្រង់ត្រូវរួចខ្លួននោះ ត្រូវតែយកទៅបិទនៅសាលាជំរះក្តី ដែលបានជំនុំជំរះរឿង និងនៅទីស្នាក់ការនៃគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់នៃលំនៅស្ថានរបស់ទណ្ឌិត ។

## អវសានបញ្ញត្តិ

**មាត្រា ២៣៧.\-**

បទបញ្ញត្តិនៃអត្ថបទច្បាប់ទាំងឡាយណាដែលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៣៨.\-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៩៩៣ នាសម័យរបជុំលើកទី ២៤ នីតិកាលទី១ ។

ធ្វើនៅភ្នំពេញ. ថ្ងៃទី ២៩ ខែមករា ឆ្នាំ ១៩៩៣

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា

ជា ស៊ីម